ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច ខូអិលធីឌី

THE PROCESS OF FINANCIAL MANAGEMENT OF

N.C.X. CO.,LTD

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច ខូអិលធីឌី

THE PROCESS OF FINANCIAL MANAGEMENT OF N.C.X. CO.,LTD.

គ្រូណែនាំ៖ ឌី រំដួល

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទៈដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនពាណិជ្ជកម្ម**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ឌី រំដួល

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

**បណ្ឌិត ហ៊ី គុជគន្ធលីនណា**

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមកក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេសក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្នក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យ និងហិរញ្ញវត្ថុ និងធនាគារតាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទី១ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ការអនុវត្តន៍ការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្តន៍ ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមរបស់យើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះពិតមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច"យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការផ្តល់ឥណទានរបស់ធនាគារ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំសូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនាដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



**ហ៊ី ម៉ីជូ**
ID:  B22/1492



**ច័ន្ទ ធុន្ធាម៉ូនិកា**
ID: B22/1245



**ហួ ឡៃអ៊ីម**
ID: B22/1355



**ឃឿន សាវតា**
ID: B22/327



**មួច អាលីហ្សា**
ID: B22/851

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញគណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្តដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសម្តែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងបានផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **ឌី រំដួល** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។ សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញលើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំរហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះផងដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២ ៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "**ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច**" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥
**ហត្ថលេខាតំណាងក្រុម**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

N.C.X CO.,Ltd គឺជាក្រុមហ៊ុនឈានមុខគេលើពិភពលោកក្នុងការផលិត រថយន្ត ម៉ូតូដែលមានមូលដ្ឋាននៅប្រទេសជប៉ុន រួចបានជ្រៀតចូលទីផ្សារកម្ពុជាក្នុងនាម Phnom Penh Honda ក្នុងឆ្នាំ1992 និងនៅក្នុងឆ្នាំ1999 បានចាប់ផ្តើមនាំចូលម៉ូតូ Honda មកកាន់កម្ពុជារួចបានស្វាគមន៍ Honda ចូលទៅកាន់ទីផ្សារកម្ពុជា។ N.C.X បានប្តេជ្ញាចិត្តក្នុងការលើកកម្ពស់វិស័យហិរញ្ញវត្ថុ ជំរុញកំណើនសេដ្ឋកិច្ច និងផ្តល់ការវិនិយោគក្នុងវិស័យយានយន្ត ជាពិសេសជាអ្នកផ្គត់ផ្គង់ និងផលិតម៉ូតូ Honda នៅប្រទេសកម្ពុជា។ N.C.X មានគោលបំណងដើម្បីបង្ហាញពីវិធីសាស្រ្ត និងការអនុវត្តន៍ក្នុងការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុនឱ្យមានប្រសិទ្ធភាព ព្រមទាំងសិក្សាឱ្យស៊ីជម្រៅបន្ថែមទៀតទៅលើគុណសម្បត្តិ និងគុណវិបត្តិនៃការគ្រប់គ្រងសាច់ប្រាក់ ដែលក្រុមហ៊ុនកំពុងអនុវត្តនៅក្នុងដំណើរការអាជីវកម្មរបស់ខ្លួន រួមទាំងបង្ហាញនូវផលិតផលរបស់ក្រុមហ៊ុន N.C.X ដែលកំពុងចរាចរលក់នៅលើទីផ្សារ។ ក្រុមហ៊ុនបានគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព ដោយអ្នកដឹកនាំមានទស្សនវិស័យក្នុងការចាយវាយ និងទុកដាក់សាច់ប្រាក់ច្បាស់លាស់ទៅតាមគោលនយោបាយ និងគម្រោងថវិកាដែលបានកំណត់។ លើសពីនេះទៅទៀតនោះ ក្រុមហ៊ុនមានវិធីសាស្រ្តក្នុងការគ្រប់គ្រងសាច់ប្រាក់ ក៏ដូចជាមានការកំណត់គម្រោងថវិកាយុទ្ធសាស្រ្តនៃការយកលុយបង្កើតលុយ គ្រប់គ្រងគណនីត្រូវទទួល និងគ្រប់គ្រងគណនីត្រូវទូទាត់បានយ៉ាងច្បាស់លាស់។ ការគ្រប់គ្រងសាច់ប្រាក់ បានត្រឹមត្រូវបានផ្តល់គុណសម្បត្តិជាច្រើន ដូចជាលំហូរសាច់ប្រាក់មានស្ថេរភាព ចំណូល និងចំណាយមានភាពច្បាស់លាស់ និងមានប្រសិទ្ធភាព។ ក្រុមហ៊ុនមានហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការប្រើប្រាស់ក្នុងដំណើរការអាជីវកម្ម និងដោះស្រាយបញ្ហាបានទាន់ពេលវេលា។

ក្រោយពីបានសិក្សាស្រាវជ្រាវកន្លងមកក្រុមយើងខ្ញុំយល់ឃើញថា ក្រុមហ៊ុនមានលទ្ធភាព ពង្រីកទំហំអាជីវកម្មរបស់ខ្លួនទាំងក្នុងពេលបច្ចុប្បន្ន និងពេលអនាគត។ ប៉ុន្តែការគ្រប់គ្រងសាច់ប្រាក់ ក៏បានផ្តល់នូវគុណវិបត្តិដល់ក្រុមហ៊ុនផងដែរ ប្រសិនបើក្រុមហ៊ុនមិនបានគិតគូរពិចារណាឱ្យបានល្អិតល្អន់។ ជាក់ស្តែង ដូចជាកង្វះខាតសាច់ប្រាក់បម្រុង កាលណាបើក្រុមហ៊ុនចំណាយថវិកាតាមគម្រោងច្រើនពេកធ្វើឱ្យក្រុមហ៊ុន មិនមានលទ្ធភាពដោះស្រាយបញ្ហាដែលអាចកើតឡើងដោយមិនបានដឹងជាមុនដូចជា គ្រោះធម្មជាតិ ឬបញ្ហាផ្សេងៗ ដែលត្រូវការចំណាយថវិកាច្រើនដើម្បីដោះស្រាយ។ លើសពីនេះទៅទៀតនោះ ក្រុមហ៊ុនក៏មានជួបនូវបញ្ហាមួយចំនួនផ្សេងទៀត ដែលមានផលប៉ះពាល់ដល់ដំណើរការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុនផងដែរដូចជាយឺតយ៉ាវក្នុងដំណើរការផលិតកម្មកង្វះខាតបុគ្គលិក និងយឺតយ៉ាវក្នុងការបង្វិលសងដល់អតិថិជន។

សរុបសេចក្តីមក ក្រុមហ៊ុនផលិតម៉ូតូ N.C.X ពិតជាមានយុទ្ធសាស្រ្តក្នុងការគ្រប់គ្រងសាច់ប្រាក់ឱ្យមានប្រសិទ្ធភាព និងមានស្ថេរភាពដោយមានទាំងសវនកម្មផ្ទៃ ក្នុងនៅក្នុងការត្រួតពិនិត្យរបាយការណ៍មាន រចនាសម្ព័ន្ធចាត់តាំងច្បាស់លាស់ អ្នកដឹកនាំមានគោលការណ៍ច្បាស់លាស់ និងទស្សនៈវិស័យត្រឹមត្រូវព្រមទាំងមានបទពិសោធន៍ និងជំនាញក្នុងការកំណត់គោលដៅទៅលើការចំណាយប្រចាំថ្ងៃព្រមទាំងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងគណនេយ្យ (Quick Book) ដែលស្របតាមគណនេយ្យផងដែរ។ ដូច្នេះ ក្រុមយើងខ្ញុំសង្ឃឹមថាក្រុមហ៊ុន N.C.X និងបន្តអនុវត្តន៍ពង្រឹងបន្ថែមទៅលើចំណុចខ្លាំងរបស់ខ្លួន ឱ្យកាន់តែមានភាពល្អប្រសើរឡើងបន្ថែមទៀតដើម្បីឱ្យក្រុនហ៊ុនទទួលបានភាពរីកចម្រើន និងភាពជោគជ័យទ្វេងងផងដែរ។

# មាតិកា

ទំព័រ


អារម្ភកថា ........ i
របនាសម្ព័ន្ធ ........ ii
សេចក្តីថ្លែងអំណរគុណ ........ iii
អំណះអំណាង ........ iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi


## ជំពូកទី១
## សេចក្តីផ្តើម


១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១ ទំហំដែនកំណត់ ........ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៧ របនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣


## ជំពូកទី២
## រំលឹកទ្រឹស្តី


២.១ ផែនការនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ ........ ៤
២.១.១ និយមន័យហិរញ្ញវត្ថុ ........ ៤
២.១.២ ប្រវត្តិហិរញ្ញវត្ថុ ........ ៤
២.១.៣ ទ្រឹស្តីហិរញ្ញវត្ថុ ........ ៤
២.២ លក្ខណៈទូទៅនៃការធ្វើផែនការហិរញ្ញវត្ថុ ........ ៥
២.២.១ និយមន័យនៃការធ្វើផែនការ ........ ៥
២.២.២ ដំណើរការនៃធ្វើផែនការក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ........ ៥
២.២.៣ ប្រភេទនៃការធ្វើផែនការ ........ ៦
២.២.៤ សារៈសំខាន់នៃការធ្វើផែនការ ........ ៦
២.៣ យុទ្ធសាស្ត្រនៃការគ្រប់គ្រងសាច់ប្រាក់ឱ្យមានប្រសិទ្ធភាព ........ ៧
២.៣.១ និយមន័យយុទ្ធសាស្ត្រ ........ ៧

២.៣.២ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងសាច់ប្រាក់..........៧
២.៣.៣ វិធីសាស្ត្រគ្រប់គ្រងសាច់ប្រាក់ឱ្យបានត្រឹមត្រូវ..........៩

**ជំពូកទី៣**

**លទ្ធផលនៃការស្រាវជ្រាវ**

៣.១ ស្ថានភាពទូទៅនៃក្រុមហ៊ុន អិន ស៊ី អិច..........១០
៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន អិន ស៊ី អិច..........១០
៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់ក្រុមហ៊ុន អិន ស៊ី អិច..........១២
ក.ចក្ខុវិស័យ..........១២
ខ.បេសកកម្ម..........១២
៣.១.៣ តួនាទី និងភារៈកិច្ចនៃក្រុមហ៊ុន អិន ស៊ី អិច..........១៨
៣.២ ផែនការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច..........១៨
៣.២.១ ការរៀបចំផែនការហិរញ្ញវត្ថុក្នុងក្រុមហ៊ុន..........១៨
៣.២.២ ការអនុវត្តន៍ផែនការរបស់ក្រុមហ៊ុន អិច ស៊ី អិច..........១៩
៣.២.៣ គុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើផែនការក្នុងក្រុមហ៊ុន..........២០
៣.៣ យុទ្ធសាស្ត្រក្នុងការបង្កើនចំណូលនិងគ្រប់គ្រងចំណាយឱ្យមានប្រសិទ្ធិភាព..........២១
៣.៣.១ ការបង្កើនចំណូលរបស់ក្រុមហ៊ុន..........២១
៣.៣.២ ការគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុន..........២៣
៣.៣.៣ ប្រភពចំណូលចំណាយសំខាន់ៗរបស់ក្រុមហ៊ុន អិច ស៊ី អិច..........២៤

**ជំពូកទី៤**

**ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ**

៤.១ ការវិភាគលើចំណុចខ្លាំង..........២៩
៤.២ ការវិភាគលើចំណុចខ្សោយ..........២៩

**ជំពូកទី៥**

**សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

៥.១ សេចក្តីសន្និដ្ឋាន..........៣០
៥.២ ការផ្តល់អនុសាសន៍..........៣១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ជាទូទៅនៅក្នុងពិភពលោកនេះមិនថាប្រទេសអភិវឌ្ឍ ឬប្រទេសដែលកំពុងអភិវឌ្ឍតែងតែមានការធ្វើពាណិជ្ជកម្ម ដើម្បីស្វែងរកប្រាក់ចំណូលមកបំពេញតម្រូវការរបស់គ្រួសារ ក៏ដូចជាជួយសេដ្ឋកិច្ចប្រទេសជាតិឱ្យរីកចម្រើនផងដែរ។ បើយើងក្រឡេកទៅមើលនាពេលសម័យលង្វែកវិញ ការធ្វើពាណិជ្ជកម្មបែបលក្ខណៈខ្នាតតូចគ្រាន់តែលក់ដូរដោយធ្វើការដោះដូរគ្នាទៅវិញទៅមក និងអាចទទួលបានប្រាក់ចំណូលបន្តិចបន្តួចដោយសារប្រព័ន្ធទីផ្សារមិនសូវទូលំទូលាយ។ តែនាពេលបច្ចុប្បន្នដោយសារប្រព័ន្ធគ្រប់គ្រង និងការដឹកនាំល្អមានភាពប្រាស្រ័យទាក់ទងល្អ និងគ្នាជាមួយប្រទេសជិតខាងបានធ្វើឱ្យវិស័យពាណិជ្ជកម្មមានការរីកចម្រើន និងផ្នែកវិទ្យាសាស្ត្រ ក៏កាន់តែទំនើបបានធ្វើឱ្យប្រទេសដែលកំពុងអភិវឌ្ឍកាន់តែមានសក្តានុពលក្លាយខ្លួនទៅជាប្រទេសអភិវឌ្ឍនាពេលអនាគតផងដែរ។

ភាពជឿទុកចិត្តដែលអាចជម្រុញអ្នកវិនិយោគទុនក្នុងតំបន់ ម្ចាស់ផ្តល់ជំនួយ ស្ថាប័នមីក្រូហិរញ្ញវត្ថុ និងប្រទេសលើសកលលោកសម្រេចចិត្តដាក់ធនធានរបស់ពួកគេមកវិនិយោគ ផ្តល់ជំនួយ និងប្រាក់កម្ចីនៅក្នុងប្រទេស ឬតំបន់មួយអាស្រ័យលើកត្តាជាច្រើនដូចជា សុខសន្តិភាព ស្ថេរភាពហិរញ្ញវត្ថុរបស់អង្គភាពមួយ ឬការសុំមូលនិធិក្នុងគម្រោងអ្វីមួយលុះត្រាតែអង្គភាពស្ថាប័ននោះផ្តល់នូវរបាយការណ៍ហិរញ្ញវត្ថុ ទើបអាចឱ្យពួកគេហ៊ានរកស៊ី សម្រេចចិត្តផ្តល់ជំនួយ កម្ចីដល់អង្គភាព ឬស្ថាប័ននោះ។ នៅក្នុងប្រទេសកម្ពុជាយើងមានក្រុមហ៊ុនពាណិជ្ជកម្មជាច្រើនតែក្នុងប្រធានបទនេះយើងខ្ញុំសូមលើកយកតែក្រុមហ៊ុនមួយមកបកស្រាយទេគឺ ក្រុមហ៊ុន អិន ស៊ី អិច តើប្រព័ន្ធនៃការគ្រប់គ្រងហិរញ្ញវត្ថុមានលក្ខណៈយ៉ាងដូចម្តេចដែរ?

ហេតុដូចនេះទើបក្រុមរបស់នាងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទស្តីពីដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនពាណិជ្ជកម្មយកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាសារណាបញ្ចប់ការសិក្សា។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្រុមហ៊ុន អិន ស៊ី អិច នាពេលបច្ចុប្បន្នដែលកំពុងរីកចម្រើន និងបន្តមានសក្តានុពលរបស់ខ្លួនក្នុងការជួយពង្រឹង ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាឱ្យកាន់តែរីកចម្រើនជឿនលឿនទៅមុខបន្ថែមទៀត។ ក្រុមហ៊ុន អិន ស៊ី អិច ជាក្រុមហ៊ុនមួយដែលប្រតិបត្តិការជាផ្លូវការនៅកម្ពុជាតាំងពីឆ្នាំ១៩៩២ មកម្ល៉េះ។ យើងមើលឃើញថា ក្រុមហ៊ុននេះបានយកចិត្តទុកដាក់យ៉ាងខ្លាំង ចំពោះផលិតផលសេវាកម្មរបស់ខ្លួនទៅកាន់អតិថិជន។ ទើបទទួលបានការយកចិត្តទុកដាក់ជឿជាក់ពីសំណាក់ប្រជាជនក្នុងប្រទេសកម្ពុជាធ្វើឱ្យក្រុមហ៊ុន អិន ស៊ី អិច ពង្រីកខ្លួនរហូតមានសាខា៤០៥ សាខា (បើគិតត្រឹមឆ្នាំ២០០៧)។ ដោយមានហេតុផលខាងលើទើបក្រុមនាងខ្ញុំមានសំណួរមួយចំនួនដូចខាងក្រោម៖

១.តើក្រុមហ៊ុន អិន ស៊ី អិច មានផែនការដូចម្តេចដើម្បីគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព?

២.តើក្រុមហ៊ុនមានយុទ្ធសាស្ត្រអ្វីខ្លះក្នុងការបង្កើនចំណូល និងគ្រប់គ្រងចំណាយមានឱ្យប្រសិទ្ធភាព?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

តាមការស្រាវជ្រាវមួយនេះ គឺត្រូវបានផ្តោតទៅលើ ការវិភាគលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច ដែលធ្វើឡើងក្នុងគោលបំណងចម្បងរួមមាន៖

- ការសិក្សាអំពីស្ថានភាពទូទៅរបស់ក្រុមហ៊ុន អិន ស៊ី អិច
- ការសិក្សាអំពីស្ថានភាពរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច
- ការសិក្សាអំពីវិធីសាស្ត្រក្នុងការវិភាគទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច ក្នុងឆ្នាំ( Income Statement, Balance Sheet, Cash Flow Statement )
- ការសិក្សាស្រាវជ្រាវទៅលើកត្តាផ្សេងៗដែលមានការបង្ហាញអំពីសក្តានុពលក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុន អិន ស៊ី អិច។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ក្រុមនាងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវ និងធ្វើការផ្តោតសំខាន់ទៅលើតែ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច តែប៉ុណ្ណោះ។ ហេតុដូចនេះក្រុមរបស់នាងខ្ញុំមិនបានសិក្សាឱ្យស៊ីជម្រៅ និងលម្អិតទៅលើកត្តាផ្សេងៗរបស់ក្រុមហ៊ុនទាំងមូលនោះទេ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺយើងបានទិន្នន័យ ដកស្រង់នៅក្នុងក្រុមហ៊ុន អិន ស៊ី អិច ខូអិលធីឌី ដែលជាក្រុមហ៊ុនពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា ហើយបានកំណត់ត្រឹមឆ្នាំ ២០២៤។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវដែលប្រើប្រាស់តាមវិធីសាស្ត្រគុណវិស័យ ដោយផ្តោតចម្បងទៅលើការវិភាគទិន្ន័យ និងឯកសារដែលពាក់ព័ន្ធទៅនឹងប្រធានបទដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់អំពីដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច ឱ្យមានប្រសិទ្ធភាព៖

➢ **សម្រាប់សំណួរស្រាវជ្រាវទី១៖** ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យដូចជា ការវិភាគលើរបាយការណ៍កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្តាញសង្គមរបស់ក្រុមហ៊ុនផ្ទាល់ការសិក្សា ស្រាវជ្រាវព័ត៌មានខ្លះៗ បានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ក្នុងការដកស្រង់នូវឯកសារមេរៀនទាំងឡាយណា ដែលពាក់ព័ន្ធទៅនឹងប្រធានបទការអានកម្រងឯកសារផ្សេងៗ ព្រមទាំងរបាយការណ៍ចាស់ៗ ដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅអ្នកគ្រូណែនាំបន្ថែម។

➢ **សម្រាប់សំណួរស្រាវជ្រាវទី២៖** ការស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រតាមបែបគុណវិស័យ ដូចជាការវិភាគលើរបាយការណ៍ កម្រងឯកសារនានា វិធីសាស្ត្រស្រាវជ្រាវតាមរយៈគេហទំព័រ បណ្តាញសង្គមរបស់ក្រុមហ៊ុនផ្ទាល់ ការសិក្សាស្រាវជ្រាវព័ត៌មានខ្លះៗបានមកពីបណ្ណាល័យរបស់សាកលវិទ្យាល័យវ៉ាន់ដា ក្នុងការដកស្រង់នូវឯកសារមេរៀនទាំងឡាយណា ដែលពាក់ព័ន្ធនឹងប្រធានបទការអានកម្រងឯកសារផ្សេងៗទៀត ព្រមទាំងរបាយការណ៍ចាស់ៗ ដែលសិស្សច្បងជំនាន់មុនបានធ្វើរួច និងធ្វើការសាកសួរទៅអ្នកគ្រូណែនាំបន្ថែម។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

១.សម្រាប់អ្នកស្រាវជ្រាវ

- យល់ដឹងពីផែនការក្នុងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាព
- យល់ដឹងពីច្បាស់ពីចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់ក្រុមហ៊ុន
- ផ្តល់ជាឯកសារសម្រាប់ជំនួយដល់និស្សិតជំនាន់ក្រោយបានសិក្សាស្រាវជ្រាវព័ត៌មានបន្ថែម។

២.សម្រាប់ស្ថាប័ន

- បង្ហាញពីទីផ្សារ ការគ្រប់គ្រងយុទ្ធសាស្ត្រក្នុងការលក់
- បង្ហាញពីការអនុវត្តន៍ជាក់ស្តែងនៅក្នុងក្រុមហ៊ុន អិន ស៊ី អិច
- បង្ហាញពីដំណើរការនៃការគ្រប់គ្រងរបស់ក្រុមហ៊ុន អិន ស៊ី អិច កាន់តែច្បាស់
- ផ្តល់ជាឯកសារដល់បុគ្គលិកក្នុងក្រុមហ៊ុន ដើម្បីជាជំនួយបំពេញនូវចំណុចខ្វះខាតក្នុងការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងសាច់ប្រាក់។

៣.សម្រាប់សង្គមជាតិ

- បង្កើតឱកាសការងារសម្រាប់ប្រជាជនទាំងបុគ្គលិកផ្នែករដ្ឋបាល បច្ចេកទេស និងផ្នែកលក់
- ជួយបង្កើនចំណូលពន្ធរដ្ឋតាមរយៈពន្ធនាំចូល និងពន្ធលើប្រាក់ចំណេញ
- ក្រុមហ៊ុនមានសកម្មភាពសប្បុរធម៌ និងអភិវឌ្ឍសហគមន៍
- ជួយសហគមន៍ក្នុងការដឹកជញ្ជូនទំនិញ និងធ្វើដំណើរងាយស្រួលជាងមុន។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនេះក្រុមយើងខ្ញុំបែងចែកជា៥ជំពូក បង្ហាញដូចខាងក្រោម៖

♦ **ជំពូកទី១៖** សេចក្តីផ្តើម បង្ហាញពីការចាប់ផ្តើមពីលំនាំបញ្ហាចំណោទបញ្ហានៃការស្រាវជ្រាវ វិសាលភាពនិងវិធីសាស្ត្រស្រាវជ្រាវ។

♦ **ជំពូកទី២៖** រំលឹកទ្រឹស្តីនៅក្នុងជំពូកនេះនិយាយបកស្រាយពីទ្រឹស្តីដែលពាក់ព័ន្ធ នឹងការរៀបចំគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុនហុងដា។

♦ **ជំពូកទី៣៖** លទ្ធផលនៃការស្រាវជ្រាវជំពូកនេះ មានការស្រាយបំភ្លឺពីប្រវត្តិលក្ខណៈទូទៅរបស់ក្រុមហ៊ុនព្រមទាំងគោលការណ៍រចនាសម្ព័ន្ធបេសកកម្ម និងតួនាទីភារៈកិច្ចរបស់ក្រុមហ៊ុន អិន ស៊ី អិច។

♦ **ជំពូកទី៤៖** ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមហ៊ុន។

♦ **ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន ការផ្តល់អនុសាសន៍ ជំពូកនេះមានការបង្ហាញពី ចំណុចសំខាន់ៗទាក់ទងទៅនឹងវិធីសាស្ត្រគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងផ្តល់ជាអនុសាសន៍សម្រាប់កែលម្អលើចំណុចខ្វះខាតខ្លះៗឱ្យប្រសើរឡើង។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# ដំណើរការនៃការធ្វើផែនការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន

## ២.១ ផែនការនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ

### ២.១.១ និយមន័យហិរញ្ញវត្ថុ

ហិរញ្ញវត្ថុ គឺជាការគ្រប់គ្រងមូលនិធិ និងទ្រព្យសម្បត្តិដើម្បីធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹងបែងចែកធនធាន និងបង្កើនប្រសិទ្ធភាពប្រតិបត្តិការហិរញ្ញវត្ថុ[1]។

ហិរញ្ញវត្ថុ គឺជាមុខវិជ្ជាមួយដែលសិក្សាពីការគ្រប់គ្រង បេតិកភណ្ឌបុគ្គល បេតិកភណ្ឌសហគ្រាស ឬបេតិកភណ្ឌសាធារណៈ។

ហិរញ្ញវត្ថុ គឺសំដៅលើមុខវិជ្ជាមួយបែបដែលសិក្សាពីការគ្រប់គ្រងរូបិយវត្ថុឱ្យមានប្រសិទ្ធភាព។

ហិរញ្ញវត្ថុ គឺជាវិន័យពាណិជ្ជកម្មដែលពាក់ព័ន្ធ និងការគ្រប់គ្រងរូបិយវត្ថុប្រកបដោយប្រសិទ្ធភាព។

### ២.១.២ ប្រវត្តិហិរញ្ញវត្ថុ

រូបិយវត្ថុ ជាចំណែកមួយនៅក្នុងជីវភាពប្រចាំថ្ងៃរបស់យើងដែលប្រព្រឹត្តទៅឥតឈប់ឈរនេះ ហើយគេចាត់ទុកមុខងារចំបាច់របស់វាជា ប្រេងរំអិល នៃសកម្មភាពសេដ្ឋកិច្ច។ ការសិក្សាសេដ្ឋកិច្ចនៃរូបិយវត្ថុ គឺជាការពិចារណាយ៉ាងស៊ីជម្រៅពីមុខងាររបស់សេដ្ឋកិច្ចទីផ្សារបែបទំនើប និងមាគ៌ាដែលរដ្ឋាភិបាលអាចនឹងត្រួតពិនិត្យទៅលើភាពគ្មានការងារធ្វើ(និកម្មញភាព) និងអតិផរណា។ នៅពេលដែលរូបិយវត្ថុ រៀបចំបានល្អផលិតផលអាចកើតឡើងសន្សឹមៗ ដោយគ្មានការអាក់អួលទន្ទឹមនឹងថ្លៃមានស្ថេរភាព។ ប៉ុន្តែមានពេលខ្លះរូបិយវត្ថុមានការប្រែប្រួល និងមានការអាក់អួលដែលអាចបណ្តាលឱ្យបរិមាណរូបិយវត្ថុកើនឡើងបានយ៉ាងឆាប់រហ័ស ឬក៏ត្រូវថយចុះច្រើនដែរហើយអតិផរណា ឬការធ្លាក់ថ្លៃប្រាកដជា និងកើតឡើងតាមគន្លងនៃការប្រែប្រួលរបស់រូបិយវត្ថុនេះជាមិនខាន។ ការស្ទាបស្ទង់បញ្ហារបស់សេដ្ឋកិច្ចបច្ចុប្បន្ន ចាប់តាំងពីអតិផរណាកម្រិតធ្ងន់ដែលកើតមាននៅអាមេរិចខាងត្បូង រហូតដល់ភាពច្របូកច្របល់នៃសេដ្ឋកិច្ចសហភាពសូវៀត ដល់ការបរាជ័យក្នុងការសន្សំ និងការកម្ចីរបស់សហរដ្ឋអាមេរិក ដែលជានិច្ចកាលគេរកឃើញវិបត្តិនេះ នៅក្នុងការគ្រប់គ្រងចាត់ចែងរូបិយវត្ថុ និងហិរញ្ញប្បទាន[2]។

### ២.១.៣ ទ្រឹស្តីហិរញ្ញវត្ថុ

នៅឆ្នាំ១៤៩៤សៀវភៅដំបូងស្តីពីគណនេយ្យហិរញ្ញវត្ថុត្រូវបានបោះពុម្ពផ្សាយនៅក្នុងទីក្រុង Venice - the treatise On Accounts and Records ។ អ្នកនិពន្ធ គឺជាអ្នកវិទូជនជាតិអ៊ីតាលីដ៏ល្បីល្បាញ គឺ Pacioli ។ នៅក្នុងសន្ធិសញ្ញានេះ បានបង្ហាញអំពីវិធីសាស្ត្រ ដើម្បីធ្វើឱ្យប្រតិបត្តិការពាណិជ្ជកម្ម ហើយនៅក្នុងទិន្នន័យគណនេយ្យត្រូវបានវាយតម្លៃនៃក្រុមហ៊ុននេះ និងការរំពឹងទុកនាពេលអនាគត។ ធនាគារ និងស្ថាប័នផ្តល់ប្រាក់កម្ចីផ្សេងៗទៀត និងមានទិន្នន័យគណនេយ្យជាច្រើនសម្រាប់ធ្វើការសម្រេចចិត្តក្នុងការផ្តល់ប្រាក់ឱ្យនូវកម្ចី ឬឥណទាន។ ប៉ុន្តែក្នុងការបង្កើតប្រព័ន្ធមួយដែលបានចំណាយពេលវេលាជាច្រើន។

សព្វថ្ងៃគណនេយ្យហិរញ្ញវត្ថុ គឺជាផ្នែកមួយនៃវិជ្ជាជីវៈធំជាងគេនៅសហរដ្ឋអាមេរិច។ ពាណិជ្ជកម្មត្រូវបានគ្របដណ្តប់នៅសហរដ្ឋអាមេរិចដោយក្រុមហ៊ុនគណនេយ្យធំរួមបញ្ចូលទាំង Deloitte, Ernst & Young.

---

[1] LAWANDMORE. (2025). *ហិរញ្ញវត្ថុជាអ្វី?* Retrieved from https://lawandmore.today/

[2] វិគីភីឌា. (2020, June 08). *ប្រវត្តិហិរញ្ញវត្ថុ.* Retrieved from https://km.wikipedia.org

KPMG និង Price Waterhouse Cooper។ លើសពីនេះទៀត មានក្រុមហ៊ុនតូចៗ ជាច្រើនដែលបានជួលគណនេយ្យករដែលបម្រើអាជីវកម្ម និងស្វែងរកជំនួញពីពន្ធដោយផ្តល់ការជានាដល់វិនិយោគិន និងសវនករ។ គណនេយ្យករភាគច្រើន ត្រូវបានទាមទារឱ្យទទួលបានវិញ្ញាបនបត្រនៅថ្នាក់រដ្ឋ ឬថ្នាក់មូលដ្ឋាននេះ គឺជាការពិតនៃហិរញ្ញវត្ថុ[3]។

## ២.២ លក្ខណៈទូទៅនៃការធ្វើផែនការហិរញ្ញវត្ថុ

### ២.២.១ និយមន័យនៃការធ្វើផែនការ

ការធ្វើផែនការ គឺជាការបង្ហាញផ្លូវសម្រាប់ការប្រតិបត្តិការងារដើម្បីសម្រេចគោលដៅទៅតាមទិសដៅកំណត់ដែលវាជាការបញ្ជាក់ពីគោលបំណងជាក់លាក់ដែលអង្គភាពចង់បានហើយ និងធ្វើការសម្រេចចិត្តជាមុនទៅលើសកម្មភាពដែលត្រូវអនុវត្តន៍រួមមានការវិភាគពីស្ថានការណ៍បច្ចុប្បន្នកាលប្រមើលមើលទៅអនាគតការកំណត់ទិសដៅ និងការសម្រេចចិត្តថាតើសកម្មភាពប្រភេទណា ដែលអង្គភាពនឹងធ្វើដោយប្រើប្រាស់នូវយុទ្ធសាស្ត្រកំណត់ពីធនធាននានាដែលត្រូវការ។

ផែនការ គឺជាគម្រោងការងារណាមួយ ដែលលើកឡើងប្រកបដោយការត្រិះរិះពិចារណា មានបទដ្ឋានត្រឹមត្រូវមានលក្ខណៈវិទ្យាសាស្ត្រហើយអាចអនុវត្តបាន។

ផែនការ គឺជាដំណើរការនៃការកំណត់គោលដៅអង្គភាព និងសម្រេចចិត្តនូវវិធីដែលល្អបំផុតដើម្បីសម្រេចគោលដៅទាំងនោះ[4]។

### ២.២.២ ដំណើរការនៃធ្វើផែនការក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ

ការធ្វើផែនការហិរញ្ញវត្ថុ គឺជាឧបករណ៍សំខាន់សម្រាប់ទាំងបុគ្គល និងស្ថាប័ន។ វាអនុញ្ញាតឱ្យពួកគេតាមដានស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្នរបស់ពួកគេ និងបង្កើតយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាព ដែលនឹងជួយពួកគេសម្រេចចិត្តថាត្រូវធ្វើអ្វី និងរបៀបដើម្បីសម្រេចគោលដៅរបស់ពួកគេក្នុងរយៈពេលខ្លី។ នៅពេលបង្កើតផែនការហិរញ្ញវត្ថុដ៏រឹងមាំ កត្តាសំខាន់ គឺជាការគិតគូរពីធាតុផ្សំសំខាន់ៗនៃជីវិតហិរញ្ញវត្ថុរបស់អ្នក ដូចជាថវិកាការសន្សំ ការធ្វើផែនការអចលនទ្រព្យ និងអ្វីៗជាច្រើនទៀតមានដូចជា៖

- កំណត់ថវិកា៖ វាមិនអាចទៅរួចទេក្នុងការធ្វើផែនការហិរញ្ញវត្ថុដោយមិនដឹងពីព័ត៌មានលម្អិតនៃប្រាក់ចំណូល និងការចំណាយរបស់អ្នក។ នៅជំហាននេះ វាមានភាពសមហេតុផលក្នុងការគណនាប្រាក់ចំណូល និងការចំណាយជាប្រចាំរបស់អ្នកដូច្នេះអ្នកអាចប្រើប្រាក់សេសសល់ ដើម្បីរ៉ាប់រងបំណុលបច្ចុប្បន្នរបស់អ្នក (បំណុលកាតឥណទាន ប្រាក់កម្ចីមិនទាន់សម្រេច)។ នៅពេលដែលពួកវាត្រូវបានបង់ជាច់អ្នកអាចបន្តទៅការសន្សំ ហើយចាប់ផ្តើមគិតអំពីការប្រើប្រាស់ថវិការបស់អ្នកសម្រាប់គោលដៅរយៈពេលវែង ដូចជាការអប់រំកុមារ។ ផ្នែកថវិកានៃផែនការហិរញ្ញវត្ថុគួរតែត្រូវបានពិនិត្យឡើងវិញជាទៀងទាត់ ជាពិសេសបន្ទាប់ពីការផ្លាស់ប្តូររឿងដ៏សំខាន់ក្នុងជីវិត ដូចជាការងារថ្មី អាពាហ៍ពិពាហ៍ ការសម្រាលកូនជាដើម។
- ការវិនិយោគ៖ មានវិធីវិនិយោគផ្សេងគ្នាជាច្រើន។ វាអាចជាការថែទាំសុខភាព ការចូលនិវត្តន៍ ឬគណនីឈ្នួញកណ្តាល។ ទោះបីគោលបំណងជាអ្វីក៏ដោយ ផែនការវិនិយោគគួរតែត្រូវបានបង្កើតជាលក្ខណៈបុគ្គលដោយផ្អែកលើគោលដៅបុគ្គលការអត់ធ្មត់ចំពោះហានិភ័យដើមទុនដែលមាន។

---

3 BIRMISS. (2018). *ទ្រឹស្តីហិរញ្ញវត្ថុ.* Retrieved from https://km.birmiss.com/

4 KHsearch.com. គ្រប់គ្រង. (2020, January 11). *ដូចម្តេចដែលហៅថាផែនការ?* Retrieved from https://www.khsearch.com/qna/28221

- ការធ្វើផែនការអចលនទ្រព្យ៖ ផែនការអចលនទ្រព្យរួមបញ្ចូលព័ត៌មានលម្អិតអំពីរបៀបគ្រប់គ្រងអចលនទ្រព្យបន្ទាប់ពីម្ចាស់បានទទួលមរណភាព។ វារួមមានទាំងឯកសារច្បាប់ និងហិរញ្ញវត្ថុ ដូចជាបណ្តាំមរតក ថៃទាំសុខភាព និងលិខិតផ្ទេរសិទ្ធិ។
- ធានារ៉ាប់រង៖ នេះអាចត្រូវបានគេមើលឃើញថាជាប្រភេទនៃការវិនិយោគដើម្បីការពារអ្នក និងលុយរបស់អ្នកក្នុងគ្រាអាសន្ន។ ប្រភេទធានារ៉ាប់រងទូទៅមួយចំនួនរួមមានការធានារ៉ាប់រងអាយុជីវិត(សម្រាប់ហានិភ័យនៃការស្លាប់) ការធានារ៉ាប់រងលើកុមារ(ការអប់រំ អាពាហ៍ពិពាហ៍) និងធានារ៉ាប់រងផ្សេងៗទៀត។
- ការធ្វើផែនការពន្ធបង្កប់ន័យ គឺការវិភាគស្ថានភាពហិរញ្ញវត្ថុទូទៅ និងស្វែងរកយុទ្ធសាស្ត្រដ៏ល្អប្រសើរដើម្បីបង់ពន្ធទាបបំផុត និងការធ្វើផែនការចូលនិវត្តន៍ផ្សេងទៀត គឺជាឧបករណ៍ដែលអាចសម្រេចបានសម្រាប់ការធ្វើផែនការពន្ធប្រកបដោយប្រសិទ្ធភាព[5]។

**២.២.៣ ប្រភេទនៃការធ្វើផែនការ**

ផែនការហិរញ្ញវត្ថុអាចបែងចែកជាបីក្រុម៖

១. ការធ្វើផែនការហិរញ្ញវត្ថុរយៈពេលខ្លីបង្កប់ន័យដោះស្រាយកិច្ចការបច្ចុប្បន្ន និងបង្ហាញលទ្ធផលជាធម្មតាក្នុងរយៈពេលមួយឆ្នាំ។ ឧទាហរណ៍នៃគោលដៅផ្ទាល់ខ្លួននៅទីនេះអាចរួមបញ្ចូលការកាត់បន្ថយ ឬសងបំណុលការបង្កើតមូលនិធិសង្គ្រោះបន្ទាន់ និងច្រើនទៀត។នៅពេលនិយាយអំពីគោលដៅរបស់ក្រុមហ៊ុនពួកគេអាចទាក់ទងនឹងការវាយលុកប្រាក់ចំណូលគោលដៅការផ្តល់មូលនិធិ និងច្រើនទៀត។

២. ការធ្វើផែនការហិរញ្ញវត្ថុរយៈពេលមធ្យម គឺជាដំណាក់កាលផ្លាស់ប្តូររវាងគោលដៅរយៈពេលខ្លី និងរយៈពេលវែង។ ជាធម្មតាវាផ្តោតលើរយៈពេលរហូតដល់៥ ឆ្នាំ។ ផែនការនេះ បង្កប់ន័យថាបញ្ហាភ្លាមៗ (ដូចជាបំណុលកាតឥណទាន) ត្រូវបានដោះស្រាយ ដូច្នេះអ្នកអាចផ្តោតលើគោលដៅប្រើប្រាស់ពេលវេលាបន្ថែមទៀតដូចជាការសន្សំសម្រាប់អចលនទ្រព្យ ការចាប់ផ្តើមអាជីវកម្មជាដើម។ ក្រុមហ៊ុនអាចពិចារណាបង្កើតខ្សែផលិតផលថ្មីចូលទីផ្សារថ្មី។

៣. ការធ្វើផែនការហិរញ្ញវត្ថុរយៈពេលវែង ជាធម្មតាត្រូវបានរចនាឡើងសម្រាប់រយៈពេលលើសពី៥ឆ្នាំ ហើយត្រូវការធនធានហិរញ្ញវត្ថុដ៏ធំ។ គោលដៅរយៈពេលវែង ជាទូទៅមួយចំនួនអាចរួមបញ្ចូលទាំងការសន្សំប្រាក់សម្រាប់ការចូលនិវត្តន៍ និងការអប់រំកុមារ ការសងបំណុល នៅលើមុខជំនួញ គោលដៅហិរញ្ញវត្ថុរយៈពេលវែងអាចជាស្វ័យប្រវត្តិកម្ម ការធ្វើឱ្យលំហូរសាច់ប្រាក់កាន់តែប្រសើរឡើង ការកាត់បន្ថយការចំណាយ[6]។

**២.២.៤ សារៈសំខាន់នៃការធ្វើផែនការ**

ការធ្វើផែនការមានសារៈសំខាន់ជាច្រើនក្នុងការធ្វើអាជីវកម្មដូចជា៖

- ផែនការជួយតម្រង់ទិសដៅដល់អង្គភាពអោយធ្វើសកម្មភាពការងារបានត្រឹមត្រូវ។
- ផែនការជាមធ្យោបាយមួយសម្រាប់ប្រឈមមុខ ដោះស្រាយតម្រូវការ ឬបញ្ហាទាំងឡាយដែលឆ្លើយតបទៅនឹងសំណូមពររបស់សង្គម។
- ផែនការជាការងារចាំបាច់ដើម្បីស្រេចបាននូវគោលដៅរបស់អង្គភាព អង្គការចាត់តាំងណាមួយ។

5 Litefinance. (2024, April). *ប្រភេទនៃការធ្វើហិរញ្ញវត្ថុ*. Retrieved from https://litefinance-kh.com/blog/for-beginners/tae-phenkar-heronhnhovottho-chea-avei/

6 Litefinance. Jana Kane. (2024, April). *ធាតុផ្សំសំខាន់នៃការធ្វើផែនការហិរញ្ញវត្ថុ*. Retrieved from https://litefinance-kh.com/blog/for-beginners/tae-phenkar-heronhnhovottho-chea-avei/

- ផែនការជួយឱ្យអ្នកដឹកនាំ ដើម្បីធ្វើការសម្រេចចិត្តលើការបែងចែកធនធានទាំងឡាយ ដូចជា៖ បុគ្គលិកសម្ភារៈបរិក្ខារនិងថវិកា។ គោលបំណងរបស់អង្គភាព គឺធ្វើឱ្យការប្រើប្រាស់ធនធានទាំងនោះមានភាពប្រសើរបំផុត ដើម្បីបង្កើនបរិមាណផលិតភាព និងប្រសិទ្ធភាពការងារក្នុងអង្គភាព។
- ផែនការជួយទូទាត់ភាពមិនច្បាស់លាស់ ផែនការជួយធ្វើឱ្យកម្រិតខ្វះខ្វាយ និងកម្រិតគ្រោះថ្នាក់ថយចុះមកក្នុងកម្រិតអប្បបរិមា។
- ផែនការបង្កើតជានិយាម ឬរបបកំណត់ (Standard) ដើម្បីសម្រួលដល់ការត្រួតពិនិត្យរបស់អ្នកគ្រប់គ្រងទៀតផង។

## ២.៣ យុទ្ធសាស្ត្រនៃការគ្រប់គ្រងសាច់ប្រាក់ឱ្យមានប្រសិទ្ធភាព

### ២.៣.១ និយមន័យយុទ្ធសាស្ត្រ

*យុទ្ធសាស្ត្រ គឺជា

- សិល្បៈនៃទ័ព និងការធ្វើសកម្មភាពទាំងឡាយក្នុងការបង្កើតលទ្ធភាពនៃភាពជោគជ័យ។

- ការរៀបចំសកម្មភាពសរុបរបស់ក្រុមហ៊ុនមួយដើម្បី បង្កើតបាននូវចីរភាពនៃភាពខ្លាំងក្នុងការប្រកួតប្រជែងនិងសម្រេចបាននូវការសម្តែងសកម្មភាពឆ្នើម។

- និយាយពីជម្រើសចាំបាច់ដើម្បីសម្តែងសកម្មភាពផ្សេងៗពីគូប្រកួតប្រជែង ឬសម្តែងសកម្មភាពស្រដៀងប៉ុន្តែធ្វើតាមវិធីផ្សេងៗ[7]។

- ការកសាងការចម្លងរវាងស្ថានភាពបច្ចុប្បន្ន និងស្ថានភាពដែលចង់បាន។

***យុទ្ធសាស្ត្រ** មានន័យថា ជាសំណុំនៃផែនការដើម្បីរៀបចំគម្រោងក្នុងគោលបំណងអ្វីមួយ ដើម្បីសម្រេចទិសដៅ។ ឧទាហរណ៍៖ បង្កើតយុទ្ធសាស្ត្រឡើងក្នុ ងគោលបំណងដើម្បីអនុវត្តឱ្យទទួលបានភាពជោគជ័យ[8]។

***យុទ្ធសាស្ត្រ** គឺជាផែនការសកម្មភាពគ្រោងឡើង ដើម្បីសម្រេចបាននូវគោលដៅជាក់លាក់មួយ[9]។

***យុទ្ធសាស្ត្រ** គឺជាការកំណត់គោលដៅរយៈពេលវែង និងការជ្រើសរើសផ្លូវដែលសមស្របទៅនឹងការប្រើប្រាស់ធនធាន ដើម្បីសម្រេចគោលដៅនោះ។ វាត្រូវបានអនុវត្តក្នុងបរិបទនានាដូចជា អាជីវកម្ម ច្បាប់ យោធា និងការគ្រប់គ្រង។

***យុទ្ធសាស្ត្រ** គឺជាបែបផែន ឬផែនការរយៈពេលវែង ដែលត្រូវបានបង្កើតឡើង ដើម្បីសម្រេចគោលបំណង ឬគោលដៅជាក់លាក់មួយ។ វាជាការសម្រេចចិត្តសំខាន់ៗ ដែលត្រូវបានដាក់អនុវត្ត ដើម្បីប្រើប្រាស់ធនធាន (Resources) ឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ក្នុងបរិបទនៃការប្រកួតប្រជែង ឬភាពមិនប្រាកដប្រែសណ្ឋាន។

### ២.៣.២ យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងសាច់ប្រាក់

ភាពវិជ្ជមាននៃលំហូរសាច់ប្រាក់ គឺជាការសម្រេចបាននូវតម្រូវការមូលធនក្នុងការរក្សាប្រតិបត្តិការពាណិជ្ជកម្មក៏ដូចជាមុខជំនួញរបស់លោកអ្នកពីមួយថ្ងៃទៅមួយថ្ងៃ។ អ្វីដែលជាការស្នើរនូវបច្ចេកទេសដ៏មាន

7 KHsearch. គ្រប់គ្រង. (2020, May 29). *យុទ្ធសាស្ត្រជាអ្វី?* Retrieved from https://www.khsearch.com/qna/31418

8 thmeythmey.com. (2017, December 24). *យុទ្ធសាស្ត្រជាអ្វី?* Retrieved from https://thmeythmey.com/detail/59938

9 WordPress. (2013, February 16). *យុទ្ធសាស្ត្រជាអ្វី?* Retrieved from https://socheatorganization.wordpress.com/2013/02/16/

សារៈសំខាន់ក្នុងការគ្រប់គ្រងសាច់ប្រាក់ឱ្យបានល្អបំផុតនោះ គឺជាសាច់ប្រាក់មានក្នុងដៃ និងសាច់ប្រាក់ចំណាយលើការងារប្រចាំថ្ងៃផ្ទុយពីទ្រព្យសកម្មដូចជា កុង ឬគណនី គឺសម្រាប់ទទួលប្រាក់ ឬអចលនទ្រព្យដែលអាចដោះដូរជាសាច់ប្រាក់បាន។

- **រក្សាការចុះបញ្ជីឱ្យបានទៀងទាត់**

ការតាមដានប្រាក់ចំណូល និងចំណាយដែលពាក់ព័ន្ធដោយផ្ទាល់នឹងសាច់ប្រាក់ គឺជាមូលដ្ឋានគ្រឹះក្នុងការគ្រប់គ្រង។ ទោះជាប្រព័ន្ធដែលផ្ទុកក្នុងកុំព្យូទ័រជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតក្នុងការតាមដាននឹងរក្សាតុល្យភាពរវាងទ្រព្យសកម្មចរន្ត និងបំណុលអកម្មក៏ដោយក៏ការធ្វើផ្ទាល់ដៃអាចអនុវត្តន៍នូវកិច្ចការនេះផងដែរ។

- **ការគ្រប់គ្រងផ្ទៃក្នុង**

ការគ្រប់គ្រងសាច់ប្រាក់ គឺជាកត្តាសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវភាពជាក់លាក់ទៀងទាត់។ ដើម្បីការពារការបាត់បង់ និងធ្វើឱ្យច្បាស់លាស់ថា ពាណិជ្ជកម្មរបស់លោកអ្នកមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់បំណុល ក្នុងនោះរាប់បញ្ចូលទាំងការសរសេរគោលនយោបាយប្រើប្រាស់ឱ្យបានច្បាស់លាស់ ក៏ដូចជានីតិវិធីប្រតិបត្តិការមានលក្ខណៈស្តង់ដាដែលបង្កើតឡើងនូវឥរិយាបថរំពឹងទុក និងបង្កើតភាពអាចទទួលខុសត្រូវបាន។

- **ការព្យាករទុកនិងការរៀបចំផែនការ**

ការរៀបចំផែនការ ពីគម្រោងលំហូរសាច់ប្រាក់ក្នុងរយៈពេលវែងប្រចាំឆ្នាំ និងអំឡុងពេលខ្លីប្រចាំខែវាអាចជួយឱ្យអ្នកយល់ដឹងអំពី ការគ្រប់គ្រងសាច់ប្រាក់ប្រចាំថ្ងៃដែលចាំបាច់ ក៏ដូចជាអភិវឌ្ឍនូវយុទ្ធសាស្ត្រដែលអាចសម្រេចទិសដៅរយៈពេលវែង។ ការបញ្ចេញគំនិតល្អៗថាពេលណាទីណា និងសាច់ប្រាក់ប៉ុន្មានដែលជានិច្ចកាលមុខជំនួញរបស់អ្នកត្រូវការច្រើនបំផុត ដើម្បីរៀបចំឱ្យប្រសើរជាងមុនហើយអាចកាត់បន្ថយឬលុបបំបាត់ការខ្ចីជាប្រភពមូលនិធិរយៈពេលខ្លី។ ការវិភាគពីកំហុសឆ្គងដែលមានកន្លងមកអាចជួយឱ្យអ្នកចៀសផុតពីកំហុសច្រំដែល និងឈានដល់ការគ្រប់គ្រងសាច់ប្រាក់កាន់តែប្រសើរឡើង។

- **សាច់ប្រាក់ដែលត្រូវទទួលបាន**

នីតិវិធីក្នុងការប្រមូលប្រាក់ គឺមានសារៈសំខាន់ណាស់ក្នុងការបញ្ចូលសាច់ប្រាក់។ កត្តានេះក៏បាន រួមបញ្ចូលផងដែរប៉ុន្តែមិនត្រូវបានកំណត់នូវកត្តាផ្សេងៗដូចជា៖ ការធ្វើឱ្យបានច្បាស់លាស់នៃវិក័យបត្រប្រចាំខែទៀងទាត់ពេលវេលា ការពិនិត្យពិច័យប្រាក់ដែលទទួលបាន និងពិសោធន៍ឃើញដូចគ្នា ពីបណ្តាអតិថិជនដែលបង់ប្រាក់យឺតយ៉ាវការបង្កើតនីតិវិធីផ្សេងៗ សម្រាប់ការអនុវត្តស្របតាមការបង់យឺតយ៉ាវ ការពង្រឹងនូវគោលការណ៍ដែលណែនាំក្នុងការផ្តល់ឱ្យឥណទាន និងការបញ្ចុះតម្លៃដល់អតិថិជនដែលបានបង់ ឬទូទាត់លើវិក័យបបត្រមុនពេលកំណត់[10]។

**២.៣.៣ វិធីសាស្ត្រគ្រប់គ្រងសាច់ប្រាក់ឱ្យបានត្រឹមត្រូវ**

សារៈសំខាន់នៃការគ្រប់គ្រងសាច់ប្រាក់រួមមាន៖

10 កោះសន្តិភាព. (2015, November 20). *ការគ្រប់គ្រងសាច់ប្រាក់ឱ្យមានប្រសិទ្ធភាព*. Retrieved from https://kohsantepheapdaily.com.kh/article/133869.html

ក. ការបង្កើតនូវគម្រោងផែនការ និងការសម្រេចចិត្តការគ្រប់គ្រងលំហូរសាច់ប្រាក់បានល្អ ជាកត្តាជំរុញទឹកចិត្តដល់គ្រប់ស្ថាប័នឱ្យបង្កើតនូវយុទ្ធសាស្ត្រនៅក្នុងរយៈពេលខ្លី ឬរយៈពេលវែង ដើម្បីឱ្យអភិវឌ្ឍស្ថាប័ននាពេលអនាគត។

ខ. ការបង្ហាញពីទិសដៅជាក់លាក់នៃលំហូរសាច់ប្រាក់ និងការយល់ដឹងអំពីស្ថានភាពជាក់ស្តែងនៃចំណូល និងចំណាយផ្តល់ភាពងាយស្រួលក្នុងការកាត់បន្ថយ ឬបង្កើនការចំណាយ លើផ្នែកណាមួយដែលមានភាពចាំបាច់សម្រាប់ប្រតិបត្តិការលំហូររបស់ស្ថាប័ន។

គ. ការការពារ និងបង្កើនទំនាក់ទំនងជាមួយដៃគូ និងភាពវិជ្ជមានរបស់របាយការណ៍លំហូរសាច់ប្រាក់នៃប្រតិបត្តិការ របស់ស្ថាប័នអាចជាកត្តាមួយជំរុញឱ្យដៃគូសហការផ្សេងៗមានការចាប់អារម្មណ៍ និងបង្កើនទំនុកចិត្តនៅក្នុងការសហការជាមួយស្ថាប័ន។

ឃ. ការយល់ច្បាស់ពីពេលវេលាដើម្បីពង្រីកស្ថាប័ន និងការយល់ដឹងអំពីលំហូរសាច់ប្រាក់ជាមួយនឹងភាពជាក់លាក់នៃរបាយការណ៍លំហូរសាច់ប្រាក់នឹងជួយស្ថាប័នឱ្យដឹងអំពី ស្ថានភាពជាក់ស្តែងរបស់ស្ថាប័នដឹងអំពីពេលវេលា និងភាពត្រឹមត្រូវក្នុងការពង្រីកប្រតិបត្តិការរបស់ស្ថាប័ន[11]។

11 អង្គភាពសវនកម្មផ្ទៃក្នុង. (2024, October). *វិធីសាស្ត្រគ្រប់គ្រងសាច់ប្រាក់*. Retrieved from https://iauoffsa.gov.kh/wp-content/uploads/2024/10/

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣

# យុទ្ធសាស្ត្រក្នុងការគ្រប់គ្រងសាច់ប្រាក់ឱ្យមានប្រសិទ្ធភាព

## ៣.១ ស្ថានភាពទូទៅនៃក្រុមហ៊ុន អិន ស៊ី អិច

ក្រុមហ៊ុន N.C.X បានប្រកាសលទ្ធផលហិរញ្ញវត្ថុសម្រាប់ត្រីមាសទីបីនៃឆ្នាំហិរញ្ញវត្ថុ ២០២៤ ដែលបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។ ក្នុងរយៈពេលនេះក្រុមហ៊ុនបានរកស៊ីប្រាក់ចំណេញប្រតិបត្តិចំនួន 397.3 ពាន់លានយេន (ប្រហែល 2.58 ពាន់លានដុល្លារ) ដែលកើនឡើង 5% បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។ ការកើនឡើងនេះបានជំរុញដោយការលក់ម៉ូតូដែលមានលទ្ធផលល្អ និងអត្រាប្តូរប្រាក់ដែលអំណោយផលដោយសារប្រាក់យេនចុះថោក។ ទោះជាយ៉ាងណាលទ្ធផលនេះនៅក្រោមការព្យាករណ៍របស់អ្នកវិភាគដែលរំពឹងទុក 403.7 ពាន់លានយេន។ នៅក្នុងទីផ្សារចិន N.C.X បានជួបបញ្ហាការលក់ធ្លាក់ចុះដោយសារការប្រកួតប្រជែងកើនឡើងពីក្រុមហ៊ុនផលិតរថយន្តអគ្គិសនីនៅក្នុងស្រុកទោះជាយ៉ាងណាការលក់នៅសហរដ្ឋអាមេរិកបានបង្ហាញការកើនឡើង 9% ក្នុងរយៈពេលប្រាំបីខែដំបូងនៃឆ្នាំ២០២៤។ ក្រុមហ៊ុន N.C.X និង Nissan បានបញ្ចប់ការពិភាក្សាអំពីការរួមបញ្ចូលអាជីវកម្ម។ ប៉ុន្តែពួកគេនឹងបន្តការសហការនៅលើគម្រោង រថយន្តអគ្គិសនី និងបច្ចេកវិទ្យាឆ្លាតវៃ។ បន្ថែមពីនេះ N.C.X បានប្រកាសផែនការផ្លាស់ប្តូររៀបចំអង្គភាព និងប្រតិបត្តិការជាច្រើនដើម្បីបង្កើនសមត្ថភាពប្រកួតប្រជែងក្នុងយុគសម័យអគ្គិសនី និងបច្ចេកវិទ្យាឆ្លាតវៃ។ ការផ្លាស់ប្តូរទាំងនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៥។ នៅក្នុងផ្នែកផលិតផល N.C.X បានបង្ហាញម៉ូដែលថ្មីៗដូចជា Honda Civic Sedan Hybrid ឆ្នាំ២០២៥ ដែលមានអត្រាប្រើប្រាស់ប្រេងប្រសើរ និងបានទទួលការទទួលស្គាល់ជារថយន្តល្អបំផុតនៅអាមេរិកខាងជើង។ ទោះបីជាប្រឈមនឹងបញ្ហាជាច្រើន N.C.X បន្តធ្វើឱ្យប្រសើរឡើង និងបង្រួបបង្រួមសមត្ថភាពរបស់ខ្លួន ដើម្បីបំពេញតម្រូវការរបស់ទីផ្សារនានា និងបង្កើនសមត្ថភាពប្រកួតប្រជែងនៅក្នុងឧស្សាហកម្ម រថយន្ត។




### ៣.១.១ ប្រវត្តិរបស់ក្រុមហ៊ុន អិន ស៊ី អិច

ក្រុមហ៊ុន N.C.X CO., Ltd. គឺជាក្រុមហ៊ុនពហុជាតិសាសន៍របស់ជប៉ុនដែលផលិត រថយន្ត ម៉ូតូ ក្នុងឧបករណ៍ថាមពលដែលមានទីស្នាក់ការកណ្តាលនៅ មីណាតូ ទីក្រុងតូក្យូ ប្រទេសជប៉ុន ។ N.C.X CO., Ltd. គឺជាក្រុមហ៊ុនផលិតម៉ូតូធំបំផុតរបស់ពិភពលោកចាប់តាំងពីឆ្នាំ១៩៥៩ ដែលឈានដល់ការផលិតម៉ូតូ ៤០០ លានគ្រឿងនៅចុងឆ្នាំ២០១៩ ក៏ដូចជាក្រុមហ៊ុនផលិតម៉ាស៊ីនចំហេះខាងក្នុងធំបំផុតរបស់ពិភពលោក ដែលមានបរិមាណផលិតជាង ១៤ លានគ្រឿងជារៀងរាល់ឆ្នាំ។

## ក. ប្រវត្តិរបស់ស្ថាបនិក

ក្រុមហ៊ុន អិន ស៊ី អិច ត្រូវបានបង្កើតឡើងដោយលោក Soichiro Honda នៅខែតុលា ឆ្នាំ១៩៤៦។ លោកជាមនុស្សម្នាក់ ដែលចាប់អារម្មណ៍ជាខ្លាំងទៅលើរថយន្តចាប់តាំងពីរូបលោកនៅវ័យក្មេងម្ល៉េះហើយគាត់ធ្លាប់បើកបរ និងប្រណាំងឡានដោយប្រើប្រាស់យានយន្តមិត្តរបស់គាត់ទៀតផង។ ក្រោយមកគាត់បានសម្រេចចិត្តបើកឧស្សាហកម្មផលិតរថយន្ត ប៉ុន្តែមិនយូរប៉ុន្មានការប្រឹងប្រែងរបស់គាត់បានឱ្យផលហើយគាត់ក៏ទទួលបានការចុះកិច្ចសន្យាសម្រាប់ការផ្គត់ផ្គង់ពិស្តុង (Piston) សម្រាប់អ្នកផលិត រថយន្ត Toyota ។ តែជាសំណាងអាក្រក់គាត់បានបាត់បង់ការព្រមព្រៀងដោយសារតែផលិតផលរបស់គាត់មិនមានគុណភាពល្អតាមតម្រូវការ។ ដូច្នេះ លោកបានទៅកាន់រោងចក្រជាច្រើនក្នុងប្រទេសជប៉ុន ដើម្បីរកមើលអំពីវិធីសាស្ត្រពង្រឹងគុណភាពរបស់ម៉ាស៊ីនដោយការផលិតពិស្តុងដែលមានប្រសិទ្ធភាព។ ក្រោយមកគាត់ក៏បានចាប់ផ្តើមបង្កើតក្រុមហ៊ុនមួយមានឈ្មោះ Tokai Seiki ដើម្បីបង្កើតផលិតផលក្នុងទំហំធំមួយ។ ពេលនោះ Toyota បានទិញ 40% នៃភាគហ៊ុនរបស់ក្រុមហ៊ុន Tokai Seiki ហើយ Soichiro និង Toyota អាចសាងទំនាក់ទំនងអាជីវកម្មជាមួយគ្នាដ៏យូរអង្វែង។ ប៉ុន្តែភាពលំបាកជាច្រើនបានបំផ្លាញចំណែកដ៏ធំនៃក្រុមហ៊ុនរបស់គាត់ហេតុនេះទើបបង្ខំឱ្យ Soichiro លក់ភាគហ៊ុននូវសល់ទៅឱ្យក្រុមហ៊ុន Toyota ។ នៅឆ្នាំ១៩៤៩ បន្ទាប់ពីការតស៊ូជាច្រើនឆ្នាំ Honda ហើយនឹងក្រុមការងាររបស់គាត់អាចបញ្ចេញនូវ ម៉ូដែល D ដែលជាម៉ូតូដំបូងពួកគេបានផលិត។ ក្នុងពេលនោះតម្រូវការចំពោះទោចក្រយានយន្តដ៏មានតម្លៃទាបនេះទទួលបានចំណូលកើនឡើងវិញនៅ ឆ្នាំ១៩៦៤ (ក្រុមហ៊ុន អិន ស៊ី អិច PERI បានក្លាយជាក្រុមហ៊ុនផលិតម៉ូតូដ៏ធំក្នុងពិភពលោក)។ ពួកគេមិនបានបញ្ឈប់ត្រឹមនេះទេ តែពួកគេបានព្យាយាមបង្កើតចេញនូវលទ្ធផលផ្សេងៗ នៅក្នុងកំឡុងពេលនោះ។ ពួកគេបានបន្តពង្រីកចំណាត់ថ្នាក់នៃយានយន្តរបស់ពួកគេ ហើយបានផលិតរថយន្តដំបូងដែលមានឈ្មោះថា $500 Sport Car ។ ភាពជោគជ័យរបស់ពួកគេគ្មានដែនកំណត់ទេពួកគេបន្តបញ្ចូលរចនាម៉ូតថ្មីហើយចាប់ផ្តើមផលិតម៉ូតូ Scooter ម៉ាស៊ីន ម៉ាស៊ីនភ្លើងម៉ូតូ និងម៉ាស៊ីនបូមទឹកយ៉ាងជោគជ័យបំផុត។

ហេតុការណ៍សំខាន់ៗដែលកើតឡើងលើលោក Soichiro Honda៖

- Soichiro Honda ( Honda Sōichirō, - ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩០៦ - ថ្ងៃទី០៥ ខែសីហា ឆ្នាំ ១៩៩១) តួនាទីជាវិស្វករ និងជាអ្នកឧស្សាហកម្មជនជាតិជប៉ុន។ នៅឆ្នាំ១៩៤៦ គាត់បានបង្កើតក្រុមហ៊ុន N.C.X Co.,Ltd និងត្រួតពិនិត្យការពង្រីកខ្លួនពីរោងម៉ាស៊ីនផលិតកង់ឈើទៅជាក្រុមហ៊ុនផលិតរថយន្តនិងម៉ាស៊ីនជាពហុជាតិ។
- Soichiro និង Saki ប្រពន្ធរបស់គាត់ទាំងពីរមានអាជ្ញាប័ណ្ណបើកបរយន្តហោះឯកជន។ គាត់ក៏ចូលចិត្តជិះស្គី វាយកូនហ្គោល ប្រណាំងឡាន ជិះអេិល និងលេងបង្ហោះប៉េងប៉ោងនៅអាយុ ៧៧ឆ្នាំហើយគាត់ គឺជា វិចិត្រករដែលមានស្នាដៃខ្ពស់។
- Takeo Fujisawa (Fujisawa ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩១០ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៨៨) គឺជាពាណិជ្ជករជនជាតិជប៉ុនម្នាក់ដែលបានបង្កើត Honda Motor Co., Ltd ជាមួយក្រុមរបស់គាត់។ Fujisawa បានត្រួតពិនិត្យផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុនខណៈពេលដែលក្រុមហ៊ុនគ្រប់គ្រង ផ្នែកអភិវឌ្ឍន៍វិស្វកម្ម និង ផលិតផល។ ពួកគេរួមគ្នាបានយកក្រុមហ៊ុនពីក្រុមហ៊ុន N.C.X CO., Ltd. ផលិតម៉ាស៊ីនកង់តូចមួយទៅកាន់ក្រុមហ៊ុនផលិតរថយន្តទូទាំងពិភពលោក។ គាត់បានចូលក្រុមហ៊ុន អិន ស៊ី អិច ដែលទើបបង្កើតថ្មីនៅឆ្នាំ១៩៤៩

ហើយនៅឆ្នាំ១៩៦៤ ត្រូវបានតំឡើងឋានៈជាអនុប្រធាន។ នៅឆ្នាំ១៩៧៣ គាត់បានចូលនិវត្តន៍ពីមុខតំណែងនេះហើយបានក្លាយជាទីប្រឹក្សាសាជីវកម្មរបស់ក្រុមហ៊ុន។ បន្ទាប់ពីចូលនិវត្តន៍គាត់បានបើកហាងលក់វត្ថុបុរាណនៅ Tokyo។

ខ. ស្ថាបនិកបច្ចុប្បន្ននៃក្រុមហ៊ុន អិន ស៊ី អិច

Toshihiro Mibe គឺជាប្រធាននាយកប្រតិបត្តិ និងជានាយកតំណាងក្រុមហ៊ុន Honda Motor Co.,Ltd ដែលបានទទួលតំណែងទាំងនេះនៅខែមេសា ឆ្នាំ២០២១។ មុនពេលក្លាយជានាយកប្រតិបត្តិសកលរបស់ N.C.X លោក Mibe បានបម្រើការជានាយកគ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុន Honda Motor Co.,Ltd ចាប់ពីខែមិថុនា ឆ្នាំ២០២០ ខណៈដំណាលគ្នាកាន់តំណែងជាប្រធាន និងជានាយកតំណាងរបស់ក្រុមហ៊ុន Honda- R&D Co., Ltd តាំងពីឆ្នាំ២០១៩ ។

**៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់ក្រុមហ៊ុន អិន ស៊ី អិច**

ក.ចក្ខុវិស័យ

១. ការតាំងចិត្តជាចម្បងរបស់យើង

ការតាំងចិត្តជាចម្បងរបស់យើងក្តីគោរពចំពោះបុគ្គលគ្រប់ៗរូបក៏ដូចជាការយកចិត្តទុកដាក់ចំពោភាពសោមនស្សរីករាយទាំងបីយ៉ាង។

សេចក្តីរីករាយទាំងបីរួមមាន៖

សេចក្តីរីករាយនៃការទិញ ភាពរីករាយនៃការទិញ គឺសម្រេចបានតាមរយៈការផ្តល់ផលិតផល និងសេវាកម្មដែលលើសពីតម្រូវការនិងការរំពឹងទុករបស់អតិថិជនម្នាក់ៗ។

សេចក្តីរីករាយនៃការលក់ ភាពរីករាយនៃការលក់កើតឡើងនៅពេលអ្នកដែលចូលរួមក្នុងការលក់ និងសេវាកម្មផលិតផលក្រុមហ៊ុនហុងដាបង្កើតទំនាក់ទំនងជាមួយអតិថិជនដោយពឹងផ្អែកលើការជឿទុកចិត្តគ្នា។ តាមរយៈទំនាក់ទំនងនេះសហការី និងអ្នកចែកចាយរបស់ក្រុមហ៊ុនហុងដាជួបប្រទះនូវមោទនភាព និងភាពរីករាយក្នុងការបំពេញចិត្តអតិថិជន និងតំណាងឱ្យក្រុមហ៊ុនហុងដាដល់អតិថិជន។

សេចក្តីរីករាយនៃការបង្កើត ភាពរីករាយនៃការបង្កើតកើតឡើងនៅពេលដែលសហការី និងអ្នកផ្គត់ផ្គង់របស់ក្រុមហ៊ុនហុងដា ចូលរួមក្នុងការធ្វើរចនាការអភិវឌ្ឍវិស្វកម្ម និងផលិតផលរបស់ហុងដាដែលទទួលស្គាល់នូវអារម្មណ៍រីករាយចំពោះអតិថិជន និងអ្នកចែកចាយរបស់ខ្លួន។ ភាពរីករាយនៃការបង្កើតកើតឡើងនៅពេលដែលផលិតផលមានគុណភាពលើសពីការរំពឹងទុក ហើយយើងជួបនូវមោទនភាពចំពោះការងារដែលសម្រេចបាន។

២. គោលការណ៍របស់ អិន ស៊ី អិច



រក្សាឱ្យបាននូវទស្សនៈ ជាសកលដោយលះបង់គ្រប់យ៉ាងដើម្បីផលិតផលដែលមានគុណភាពឈានមុខគេជាមួយតំលៃសមរម្យសម្រាប់បំពេញចិត្តអតិថិជនទូទាំងសកលលោក។

**៣. គោលនយោបាយក្នុងការគ្រប់គ្រង**

- ការប្តេជ្ញាចិត្តចម្បងរបស់ក្រុមហ៊ុនយើង គឺដំណើរការដែលប្រកបដោយមហិច្ឆតា ដែលជំរុញឱ្យយើងមានការរីកចម្រើនជាមួយនឹងការប្រកួតប្រជែង។
- បំពេញការងារឱ្យបានត្រឹមត្រូវដោយអនុវត្តតាមគោលការណ៍រឹងមាំ និងមានគំនិតប្រកបដោយភាពច្នៃប្រឌិត និងប្រើប្រាស់ពេលវេលាប្រកបដោយប្រសិទ្ធភាព។
- រីករាយនឹងការងាររបស់យើង លើកកម្ពស់វប្បធម៌ និងទទួលមតិយោបល់ត្រឡប់មកវិញ។
- រក្សាកិច្ចខិតខំប្រឹងប្រែងជាប់លាប់ ដើម្បីធានាថាការងារបន្តដំណើរការទៅមុខ។
- ផ្តល់តម្លៃដល់ការស្រាវជ្រាវហ្មត់ចត់ និងការខិតខំប្រឹងប្រែង។

**៤.បេសកកម្ម**

**> នាយក/ប្រធាន**

- ដឹកនាំ និងត្រួតពិនិត្យ រាល់កិច្ចការទាំងអស់**របស់**ក្រុមហ៊ុនព្រមទាំងអនុម័តកិច្ចការនានាដោយឈរលើគោលការណ៍ និងនីតិវិធីរបស់ក្រុមហ៊ុន
- អ្នកទទួលខុសត្រូវលើរាល់ប្រតិបត្តិការរបស់អង្គភាពទាំងអស់របស់អាជីវកម្ម
- ជាអ្នកផ្តួចផ្តើមបង្កើតរូបមន្ត ឬវិធីសាស្ត្រសម្រាប់គ្រប់គ្រងដំណើរការការងារក្នុងអង្គភាពអាជីវកម្ម
- រៀបចំផែនការណ៍យុទ្ធសាស្ត្រាចាត់ចែង និងការដឹកនាំការងារក្រុមហ៊ុនរួមមាន៖

- កិច្ចការហ្វឹកហ្វឺន
- កិច្ចការទីផ្សារ
- កិច្ចការរដ្ឋបាល
- កិច្ចការគ្រប់គ្រងសាច់ប្រាក់
- កិច្ចការគណនេយ្យ និងហិរញ្ញវត្ថុ

- កិច្ចការបច្ចេកវិទ្យាព័ត៌មាន
- កិច្ចការច្បាប់
- កិច្ចការអភិបាលក្នុងក្រុមហ៊ុន

• ការទទួលខុសត្រូវលើការងារការអនុវត្តផែនការការងារទាំងការរៀបចំចាត់ចែងការងារក្នុងរង្វង់តួនាទីឱ្យបានល្អដឹកនាំឱ្យមានប្រសិទ្ធភាពត្រួតពិនិត្យវាយតម្លៃឱ្យបានត្រឹមត្រូវដោះស្រាយរាល់បញ្ហាដែលបានកើតឡើង និងកែសម្រួលឱ្យបានទាន់ពេលវេលា។

• ធានាយ៉ាងណាឱ្យការងារប្រព្រឹត្តទៅដោយរលូន និងបានលទ្ធផលប្រសើរបំផុត។



**> ប្រធានផ្នែកហិរញ្ញវត្ថុ**

• រៀបចំប្រព័ន្ធការងារ និងគ្រប់គ្រងគណនេយ្យប្រចាំខែដោយត្រូវបង្ហាញពីនីតិវិធីនៃការធ្វើការងារ និងទំនាក់ទំនងការងារទៅកាន់គ្រប់ផ្នែកទាំងអស់ឱ្យបានទាន់ពេល និងមានលក្ខណៈងាយស្រួលតាមស្តង់ដាការងារ។

• រៀបចំគម្រោងថវិកា (Budget Plan) ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

• ត្រួតពិនិត្យរាល់ការចំណាយទាំងមូលរបស់ក្រុមហ៊ុនមុនអនុម័តឱ្យចាយនូវរាល់ចំណាយផ្សេងៗមុនតាមការកំណត់។

• រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន។

• រៀបចំបញ្ជីប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗរបស់បុគ្គលិកប្រចាំខែ/ឆ្នាំ។

• ត្រួតពិនិត្យថ្លៃដើមទំនិញមុននឹងធ្វើការបញ្ជារទិញទំនិញនិងបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ។

• តាមដាន និងត្រួតពិនិត្យជាប្រចាំនូវរាល់ការងាររបស់បុគ្គលិកក្រោមឱវាទ និងដោះស្រាយរាល់បញ្ហាដែលកើតមានក្នុងផ្នែក។

• ពិនិត្យផ្ទៀងផ្ទាត់ និងរាប់សមតុល្យសាច់ប្រាក់ដែលមានជាក់ស្តែងធៀបជាមួយនឹងសមតុល្យដែលមាននៅក្នុងបញ្ជីរៀងរាល់ថ្ងៃបន្ទាប់ពីទទួលបានពីគណនេយ្យករ។

• រាយការណ៍ជូននាយកផ្ទាល់អំពីបញ្ហាទាំងឡាយណាដែលមានការពាក់ព័ន្ធនឹងចំណាយជាពិសេសចំណាយដែលមិនសមស្រប ឬខុសពីគោលការណ៍កំណត់។

• ធ្វើរបាយការណ៍បិទបញ្ជី ប្រចាំថ្ងៃ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំឱ្យត្រឹមត្រូវ និងទាន់ពេលវេលា។

**> គណនេយ្យករ**

• ទទួលខុសត្រូវក្នុងការកត់ត្រាចំណូលចំណាយរបស់ក្រុមហ៊ុន។

• ទទួលខុសត្រូវក្នុងការគ្រប់គ្រងទូទាត់សាច់ប្រាក់ និងត្រួតពិនិត្យសាច់ប្រាក់ឱ្យសមស្របទៅតាមគោលនយោបាយហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

• ធានារាល់ការចំណាយមានឯកសារភ្ជាប់ត្រឹមត្រូវ និងគោរពទៅតាមគោលការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលបានកំណត់។

• រៀបចំការងារទាក់ទងជាមួយធនាគារ ដូចជា ការផ្ទេរ ការដក និងដាក់សាច់ប្រាក់ជាដើម។

• ពិនិត្យផ្ទៀងផ្ទាត់ និងរាប់សមតុល្យសាច់ប្រាក់ដែលមានជាក់ស្តែងធៀបជាមួយនឹងសមតុល្យដែលមាននៅក្នុងបញ្ជី រៀងរាល់ថ្ងៃនីមួយៗជាមួយនឹងបេឡា។

• ទទួលខុសត្រូវក្នុងការបញ្ចូលទិន្នន័យហិរញ្ញវត្ថុទៅក្នុងប្រព័ន្ធគណនេយ្យ Quick book, Excel ។

• រៀបចំ និងត្រួតពិនិត្យ រាល់ទម្រង់ ចំណូល ចំណាយ បុរេប្បទាន។

• រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ និងផ្ញើរទៅកាន់ប្រធានផ្នែកហិរញ្ញវត្ថុ។

**> បេឡាករ**

• កត់ត្រាសាច់ប្រាក់លើវិក្កយបត្រជូនអតិថិជន និងចេញវិក្កយបត្រជូនអតិថិជន។

• ទទួល និងពិនិត្យប្រាក់ពីផ្នែកលក់ និងអតិថិជនទុកដាក់ប្រាក់នោះឱ្យមានសុវត្ថិភាព។

• រៀបចំបញ្ជីប្រាក់ចំណូល បិទបញ្ជីប្រចាំថ្ងៃ និងបញ្ជូនសាច់ប្រាក់ទាំងនោះទៅឱ្យគណនេយ្យករ។

• កត់ត្រា និងថែរក្សាសៀវភៅបេឡា សក្ខីប័ណ្ណចំណូល និងឯកសារផ្សេងៗ។

• កត់ត្រាប្រតិបត្តិការចំណូល ប្រចាំថ្ងៃចូលក្នុងប្រព័ន្ធកុំព្យូទ័ររបស់ក្រុមហ៊ុនមុនអនុម័តឱ្យត្រឹមត្រូវនូវរាល់ចំណាយផ្សេងៗមុនតាមការកំណត់។

• រក្សាព័ត៌មានផ្សេងៗទៀតដែលទាក់ទងនឹងសាច់ប្រាក់ និងអនុវត្តការងារផ្សេងៗទៀតតាមការណែនាំរបស់អ្នកគ្រប់គ្រង។

• ថែរក្សា ត្រួតពិនិត្យ និងរៀបចំសាច់ប្រាក់ឱ្យមានសណ្តាប់ធ្នាប់។

**> ផ្នែកឃ្លាំង**

• គ្រប់គ្រងស្តុកទំនិញចេញ-ចូល និងទទួលខុសត្រូវរាល់ទំនិញដែរនៅក្នុងឃ្លាំងបញ្ចូលទំនិញក្នុងស្តុក ឬឃ្លាំង។

• បញ្ចូលទិន្នន័យទំនិញចូលក្នុង System និងបញ្ចេញទំនិញជូនដល់បុគ្គលិកផ្នែកលក់។

• ត្រួតពិនិត្យកាលបរិច្ឆេទផលិត និងកាលបរិច្ឆេទផុតកំណត់របស់ផលិតផល ជៀសវាងមានការ

ប៉ះពាល់ដល់អ្នកប្រើប្រាស់ ឬអតិថិជន។

• ធ្វើការកែតម្រូវស្តុកឃ្លាំងឱ្យបានត្រឹមត្រូវក្រោយពេលរាប់រួចរាល់ប្រសិនបើមានបាត់ ឬលើស។
• រៀបចំសណ្តាប់ធ្នាប់ក្នុងឃ្លាំង និងរៀបចំទំនិញដាក់តាមទីតាំង។
• ការរៀបចំចាត់ចែងឱ្យបុគ្គលិកវេចខ្ចប់ទំនិញឡើងវិញចំពោះទំនិញដែលមានសំបកខ្ចប់ខូចមានទ្រង់ទ្រាយមិនដូចសភាពដើម ឬស្ថានភាពមិនល្អ។
• រៀបចំចាត់ចែងដឹកទំនិញជូនអតិថិជនទៅតាមការកំណត់ឱ្យបានទាន់ពេលវេលា។
• ផ្តល់ព័ត៌មានដល់អ្នកគ្រប់គ្រង អំពីពេលវេលាចាប់ផ្តើមដឹកទំនិញឱ្យអតិថិជននិងការបញ្ចប់។
• រៀបចំចាត់ចែងអ្នកបើកបរ និងទំនាក់ទំនងជាមួយអតិថិជនមុនពេលដឹកទំនិញជូនអតិថិជនតាមដានការដឹកទំនិញឱ្យអតិថិជនឱ្យបានរួចរាល់។
• ធ្វើរបាយការណ៍សមតុល្យ ទំនិញក្នុងឃ្លាំងប្រចាំថ្ងៃ ប្រចាំខែ។
• រៀបចំ និងចាត់ចែងបុគ្គលិកធ្វើការងារក្នុងឃ្លាំងសំអាតបរិវេណខាងក្រៅឃ្លាំង និងធ្វើការងារផ្សេងៗ។

> **ផ្នែកធនធានមនុស្ស**

• ទទួលខុសត្រូវចម្បងលើកិច្ចការរៀបចំធនធានមនុស្ស និងបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ការរីកចម្រើនរបស់ក្រុមហ៊ុន។
• រៀបចំដំណើរការជ្រើសរើសបុគ្គលិក។
• រៀបចំការកំណត់តួនាទី និងការផ្ទេរសិទ្ធរបស់បុគ្គលិក។
• កំណត់លទ្ធផលការងារដែលរំពឹងទុកពីបុគ្គលិក និងរៀបចំការវាយតម្លៃបុគ្គលិក។
• រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងក្នុងក្រុមហ៊ុន។

> **ប្រធានផ្នែកលក់**

• រៀបចំបង្កើតបណ្តាញទីផ្សារការផ្សព្វផ្សាយ និងរៀបផែនការបរិមាណនៃការលក់ចេញ។
• ធ្វើការអនុវត្តន៍យុទ្ធសាស្ត្រទីផ្សារ និងការលក់ឱ្យមានប្រសិទ្ធភាពដើម្បីជានាពង្រឹងការលក់ប្រចាំខែ និងប្រចាំឆ្នាំទៅតាមផែនការរបស់ក្រុមហ៊ុនដែលបានកំណត់។
• ទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ដើម្បីលើកជាគម្រោងផែនការលក់ប្រចាំឆ្នាំផ្តល់នូវការគាំទ្រ ដើម្បីឱ្យផែនការលក់នោះទទួលបានជោគជ័យ។
• ដឹកនាំ និងបង្ហាត់បង្ហាញភ្នាក់ងារលក់ឱ្យមានប្រសិទ្ធភាពរក្សាទំនាក់ទំនងឱ្យល្អ និងមានភាពជិតស្និទ្ធជាមួយអតិថិជនចាស់ស្វែងរកអតិថិជនថ្មីៗ។
• ដោះស្រាយបញ្ហាទូទៅដែលនឹងជួបប្រទះឱ្យល្អប្រសើរនិងទាន់ពេលវេលា និងតាមគោលការណ៍ក្រុមហ៊ុន។
• វិភាគទៅលើលទ្ធផលនៃការលក់ និងដំណោះស្រាយបញ្ហាផ្សេងៗដើម្បីរាយការណ៍ជូនប្រធានក្រុមហ៊ុន។
• ធ្វើការតាមដានស្ថានភាពទីផ្សារ និងគូរប្រកួតប្រជែងដើម្បីជានាការលក់ទៅតាមផែនការ។
• តាមដាន និងធ្វើការសិក្សាលើការប្រែប្រួលតម្រូវការទីផ្សារធ្វើការគ្រប់គ្រង និងពង្រីកគ្រប់បណ្តាលផលិតផលរបស់ក្រុមហ៊ុនឱ្យបានទូលំទូលាយ។
• ធ្វើការងារផ្សេងៗទៀតដែលចាំបាច់បង្គាប់ដោយនាយកក្រុមហ៊ុន។

> **ផ្នែកលក់**

- ជាអ្នករកប្រាក់ចំណូលចូលក្រុមហ៊ុន។
- ធ្វើការទំនាក់ទំនង និងធ្វើការណាត់ជួបជាមួយអតិថិជនដើម្បីបង្ហាញពីផលិតផលរបស់ក្រុមហ៊ុន។
- ធ្វើការសម្របសម្រួល និងលក់ផលិតផលជូនអតិថិជន។
- ទទួលខុលត្រូវលើសកម្មភាពនៃការលក់ប្រចាំថ្ងៃ។
- រាយការណ៍សកម្មភាពការលក់ប្រចាំថ្ងៃជូនប្រធានផ្នែកលក់។
- មានជំនាញក្នុងការដោះស្រាយបញ្ហា និងការសម្រេចចិត្ត។
- តាមដានការវិវឌ្ឍន៍របស់ទីផ្សារផលិតផលផ្តល់ព័ត៌មាន និងយោបល់ដល់ថ្នាក់គ្រប់គ្រងដើម្បីធ្វើការកែលម្អ ។

> **ផ្នែកទីផ្សារ**

- ធ្វើផែនការទីផ្សារយុទ្ធសាស្រ្ត ផែនការសកម្មភាព ផែនការថវិការសម្រាប់ផ្នែកទីផ្សារ និងអនុវត្តផែនការទាំងអស់នោះឱ្យមានប្រសិទ្ធភាពខ្ពស់។
- រៀបចំកម្មវិធី Promotion ប្រចាំខែ ប្រចាំឆ្នាំ និងអនុវត្តកម្មវិធី Promotion ឱ្យមានប្រសិទ្ធភាព។
- រៀបចំ និងដាក់ស្នើសុំការអនុម័តយល់ព្រមលើបញ្ជីតម្លៃសម្រាប់ផលិតផលទាំងអស់។
- រៀបចំឯកសារសម្រាប់ការបញ្ជាទិញផលិតផលក្នុងប្រទេសកម្ពុជា និងនាំចូលផលិតផលមកទីផ្សារ។
- តាមដានសិក្សាការប្រែប្រួលពីតម្រូវការទីផ្សារ និងស្វែងយល់ពីតម្រូវការរបស់អតិថិជន។
- ស្វែងរកអតិថិជនគោលដៅ និងសិក្សាពីដៃគូប្រកួតប្រជែង។
- ធ្វើការផ្សព្វផ្សាយផលិតផលទៅលើទីផ្សារតាមរយៈ ប្រព័ន្ធអ៊ីនធឺណេត កញ្ចក់ទូរទស្សន៍ ឬតាមមធ្យោបាយផ្សេងៗ។

> **ផ្នែកប្រព័ន្ធបច្ចេកទេស**

- គ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាក្នុងក្រុមហ៊ុន។
- ដោះស្រាយបញ្ហានៅពេលមានសំណើពីអ្នកប្រើប្រាស់។
- កំណត់បង្ហាញព័ត៌មានចាំបាច់របស់ក្រុមហ៊ុន និងកំណត់តម្រូវការចាំបាច់ក្នុងគម្រោងផែនការ។
- ធ្វើការកំណត់នូវបច្ចេកវិទ្យា និងបច្ចេកទេសដែលត្រូវអនុវត្តន៍។
- ធ្វើការបង្កើតទម្រង់ឯកសារមុខងាររៀបរាប់ពីតម្រូវការរបស់អ្នកប្រើប្រាស់អំពីប្រព័ន្ធ ដើម្បីឱ្យប្រព័ន្ធនោះបង្កើតឡើងត្រូវនឹងប្រតិបត្តិការការងារ។
- រិះរកបច្ចេកទេសប្រព័ន្ធគ្រប់គ្រងកម្មវិធីថ្មីៗ ដើម្បីគាំទ្រដល់អ្នកប្រើប្រាស់ និងក្រុមហ៊ុនទាំងមូល។
- ធានាឱ្យបាន នូវសុវត្ថិភាពនៃការជ្រៀតចូលពីសំណាក់ជនអនាមិកចូលក្នុងប្រព័ន្ធរបស់ក្រុមហ៊ុនទាំងមូលឬក៏បណ្តាញផ្សេងៗទៀតដែលមានផលមិនល្អដល់ក្រុមហ៊ុន។

* **លក្ខណៈសម្បត្តិរបស់ក្រុមហ៊ុន**

- ផ្តល់ទំនុកចិត្ត និងភាពជឿជាក់ដល់អតិថិជន និងអ្នកប្រើប្រាស់។
- មានការចូលរួមផ្តល់យោបល់គ្នាទៅវិញទៅមកដើម្បីស្ថាបនា និងអភិវឌ្ឍក្រុមហ៊ុន។
- បុគ្គលិកមានភាពទទួលខុសត្រូវខ្ពស់ចំពោះតួនាទី ការងារ។

• បុគ្គលិកមានជំនាញផ្នែកភាសាបរទេសបន្ថែមលើមុខជំនាញ។

• បង្កើតឱកាសការងារ និងពង្រីកទីផ្សារក្នុងស្រុក។

• ចូលរួមសកម្មភាពនានាជាមួយសង្គមក៏ដូចជារាជរដ្ឋាភិបាលតាមរយៈការផ្តល់ជំនួយជូនដល់ មន្ទីរពេទ្យ ជនពិការ ការចូលរួមកសាងសាលារៀន ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។

**៣.១.៣ តួនាទី និងភារកិច្ចនៃក្រុមហ៊ុន អិន ស៊ី អិច**

N.C.X មានសារៈសំខាន់ណាស់ក្នុងវិស័យឧស្សាហកម្មយានយន្ត និងបច្ចេកវិទ្យា។ ខាងក្រោមនេះ ជាការពិពណ៌នាអំពីតួនាទី និងភារកិច្ចសំខាន់ៗរបស់ N.C.X៖

**តួនាទីរបស់ក្រុមហ៊ុន N.C.X**

១. ផលិតយានយន្ត N.C.X ជាក្រុមហ៊ុនផលិតរថយន្ត និងម៉ូតូធំជាងគេមួយនៅលើពិភពលោក។ តួនាទីរបស់វាគឺផ្តល់យានយន្តគុណភាពល្អ សុវត្ថិភាព និងប្រកបដោយបច្ចេកវិទ្យាទំនើប។

២. ចំណេះដឹងបច្ចេកវិទ្យា និងការបង្កើតថ្មី N.C.X មានតួនាទីជាម្ចាស់បច្ចេកវិទ្យាថ្មីៗដូចជា ម៉ាស៊ីនប្រេងមានប្រសិទ្ធភាពខ្ពស់ ម៉ាស៊ីនអគ្គិសនី ឬម៉ាស៊ីនហាយប្រ៊ីដ (Hybrid) និងស្រាវជ្រាវលើរថយន្តអាកាស ឬបច្ចេកវិទ្យា AI។

៣. ការចូលរួមក្នុងការអភិរក្សបរិស្ថាន N.C. X មានតួនាទីក្នុងការផលិតយានយន្តដែលប្រើសាំងតិច ប្រើថាមពលស្អាតដើម្បីកាត់បន្ថយការ បំពុលបរិស្ថាន។

៤. បង្កើតការងារ និងអភិវឌ្ឍសេដ្ឋកិច្ច N.C.X ជួយបង្កើតការងារជាច្រើននៅក្នុងប្រទេសនានា និងមានការចូលរួមក្នុងការកសាងសេដ្ឋកិច្ចក្នុងតំបន់នីមួយៗ។

**ភារកិច្ចរបស់ក្រុមហ៊ុន N.C.X**

១. បំពេញតម្រូវការរបស់អតិថិជនផ្តល់ផលិតផលដែលមានគុណភាពបត់បែនទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់ និងផ្តោតលើភាពសុខស្រួល។

២. ច្នៃប្រឌិត និងការកែលម្អបន្តបន្ទាប់ N.C.X មានភារកិច្ចក្នុងការច្នៃប្រឌិតដើម្បីផ្តល់ឧបករណ៍ និងបច្ចេកវិទ្យាថ្មីៗដែលអាចបម្រើបម្រាស់យ៉ាងមានប្រសិទ្ធភាព។

៣. ការពារសុវត្ថិភាព N.C.X ទទួលខុសត្រូវក្នុងការផលិតយានយន្តដែលមានសុវត្ថិភាពខ្ពស់សម្រាប់អ្នកបើកបរ និងអ្នកដំណើរ។

៤. អភិរក្សបរិស្ថានភារកិច្ចមួយទៀត គឺការកាត់បន្ថយការបំផុសឧស្ម័នកាបូន និងអភិវឌ្ឍន៍យានយន្តបៃតង។

## ៣.២ ផែនការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច

### ៣.២.១ ការរៀបចំផែនការហិរញ្ញវត្ថុក្នុងក្រុមហ៊ុន

ការរៀបចំផែនការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច (N.C.X) គឺជាដំណើរការសំខាន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីធានាថាក្រុមហ៊ុនមានសមត្ថភាពលើផ្នែកប្រាក់ជារៀងរាល់ថ្ងៃ និងអាចសម្រេចបាននូវគោលដៅអាជីវកម្មរយៈពេលខ្លី និងវែង។ ខាងក្រោមនេះជាជំហានសំខាន់ៗក្នុងការរៀបចំផែនការហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុន N.C.X៖

១. ការវិភាគស្ថានភាពហិរញ្ញវត្ថុបច្ចុប្បន្ន

- វិភាគចំណូល និងចំណាយប្រចាំខែ/ឆ្នាំ
- វិភាគអត្រាប្រាក់ចំណេញសុទ្ធ និងអត្រាចំណាយ
- ពិនិត្យសមតុល្យរវាងទ្រព្យសម្បត្តិ និងបំណុល
- ពិនិត្យការប្រើប្រាស់ប្រាក់សុទ្ធ (Cash Flow)

២. កំណត់គោលដៅហិរញ្ញវត្ថុ

- គោលដៅខាងហិរញ្ញវត្ថុរយៈខ្លី (៣–៦ ខែ): ឧទាហរណ៍៖ ការកាត់បន្ថយចំណាយប្រតិបត្តិការ ១០% កើនចំណូលពីការលក់
- គោលដៅរយៈវែង (១–៣ ឆ្នាំ): ឧទាហរណ៍៖ បង្កើនបរិមាណទ្រព្យសម្បត្តិ បង្កើតបណ្តាញសាខាថ្មី

៣. ការរៀបចំថវិកាហិរញ្ញវត្ថុ (Budgeting)

- រៀបចំថវិកាដោយផ្អែកលើការរំពឹងចំណូល និងចំណាយ
- កំណត់ថវិកាសម្រាប់ផ្នែកផ្សេងៗ (លក់, សេវាកម្ម, សារពើពន្ធ, បុគ្គលិក)
- បែងចែកថវិកាសម្រាប់វិនិយោគ និងអភិវឌ្ឍ

៤. ការគ្រប់គ្រងប្រាក់សុទ្ធ (Cash Flow Management)

- គ្រប់គ្រងប្រាក់ចូល (Accounts receivable) និងប្រាក់ចេញ (Accounts payable)
- កំណត់ការរក្សាទុកប្រាក់សមតុល្យ
- បង្កើនប្រសិទ្ធភាពក្នុងការប្រមូលប្រាក់ពីអតិថិជន

៥. ការវិនិយោគ និងហានិភ័យហិរញ្ញវត្ថុ

- សម្រេចចិត្តលើប្រភេទវិនិយោគ (ឧទាហរណ៍ ទិញឧបករណ៍ថ្មី បង្កើតផលិតផលថ្មី)
- វិភាគហានិភ័យហិរញ្ញវត្ថុ និងបង្កើតយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ

៦. ប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ និងកម្មវិធីគណនេយ្យ

- ប្រើកម្មវិធីជំនួយដូចជា QuickBooks, Xero, SAP
- បង្កើតរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ប្រចាំត្រីមាស (Balance Sheet, Income Statement, Cash flow Statement)

៧. ការត្រួតពិនិត្យ និងវាយតម្លៃ

- ត្រួតពិនិត្យប្រតិបត្តិការផ្នែកហិរញ្ញវត្ថុជាពេលបច្ចុប្បន្ន
- កែសម្រួលផែនការបើត្រូវការតាមស្ថានភាពទីផ្សារ

**៣.២.២ ការអនុវត្តន៍ផែនការរបស់ក្រុមហ៊ុន អិច ស៊ី អិច**

ការអនុវត្តន៍ផែនការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច (N.C.X) ជាជំហានសំខាន់បន្ទាប់ពីការរៀបចំផែនការ ដើម្បីធ្វើឱ្យគោលដៅរបស់ក្រុមហ៊ុនក្លាយជាការពិត។ ដូច្នេះដំណើរការអនុវត្តន៍ផែនការដែលមានប្រសិទ្ធភាពត្រូវការច្បាស់លាស់ ការសម្របសម្រួលល្អ និងការត្រួតពិនិត្យជាប្រចាំ។ ខាងក្រោមជាចំណុចសំខាន់ៗនៃការអនុវត្តន៍ផែនការរបស់ក្រុមហ៊ុន N.C.X៖

១. ការចែកចាយផែនការទៅកាន់ផ្នែកនានា

- បែងចែកការងារទៅផ្នែកទាំងអស់៖ ផ្នែកហិរញ្ញវត្ថុ, ផ្នែកលក់,ផ្នែកទំនាក់ទំនងអតិថិជន, ផ្នែកលើកទឹកចិត្ត និងធនធានមនុស្ស។
- បញ្ជាក់នូវតួនាទី និងទំនួលខុសត្រូវ របស់នីតិវិធីនីមួយៗក្នុងការអនុវត្តផែនការ។

២. ដាក់ចេញនូវយុទ្ធសាស្ត្រ និងវិធានការប្រើប្រាស់ថវិកា

- អនុវត្តថវិកាដោយយកចំណូល និងចំណាយដាក់ស្តែងទៅប្រើ។
- អភិវឌ្ឍការគ្រប់គ្រងប្រាក់សុទ្ធ (Cash Flow) ដោយយកលទ្ធផលពីគម្រោងចំណូល និងចំណាយរបស់អង្គភាពផ្សេងៗមកសម្របសម្រួល។
- បំពេញការវិនិយោគ ទៅលើផ្នែកសំខាន់ៗដូចជា៖ ប្រព័ន្ធ ERP គុណភាពសេវាកម្មអតិថិជន បច្ចេកវិទ្យា (ឧទាហរណ៍ Mobile app N.C.X) និងផ្នែកបច្ចេកទេស។

៣. ការត្រួតពិនិត្យ និងគ្រប់គ្រង

- ដាក់ចេញគោលបំណងទិន្នន័យសំខាន់ៗ (KPIs) ដើម្បីវាស់វែងដំណើរការអនុវត្ត៖
- ភាគរយនៃការប្រើប្រាស់ថវិកា
- កំណើនប្រាក់ចំណូល
- អត្រាប្រមូលប្រាក់ពីអតិថិជន
- បង្កើតរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ដើម្បីប្រៀបធៀបការអនុវត្តន៍ជាក់ស្តែងនឹងផែនការដែលបានរៀបចំ។

៤. ការបង្កើតប្រព័ន្ធព័ត៌មាន និងការប្រាស្រ័យទាក់ទង

- ប្រើប្រាស់ ប្រព័ន្ធគ្រប់គ្រងថវិកាដែលមានប្រសិទ្ធភាព (ឧទាហរណ៍៖ (SAP, QuickBooks, Xero)
- បង្កើតប្រព័ន្ធសារព័ត៌មានក្នុងក្រុមហ៊ុន (Intranet, Email Reports) ដើម្បីឱ្យបុគ្គលិកទទួលបានព័ត៌មានទាន់ពេលវេលា។
- រៀបចំកិច្ចប្រជុំគ្រប់គ្រងថវិកា ឬ "Financial Review Meeting" ជាប្រចាំដើម្បីវាយតម្លៃ និងសម្រេចការផ្លាស់ប្តូរ។

៥. ការសម្របសម្រួល និងកែលម្អបន្ត

- ប្រសិនបើមានការប្រែប្រួលទីផ្សារ ឬបញ្ហាហិរញ្ញវត្ថុក្រៅការរំពឹងទុក N.C.X ត្រូវមានសមត្ថភាពចូលរួមកែសម្រួលផែនការ។
- ត្រូវពិនិត្យលទ្ធផលផែនការជារៀងរាល់ត្រីមាស ដើម្បីកែសម្រួលអាចធ្វើបានបើគោលដៅមិនទាន់អនុវត្តបានល្អ។
- ការពិភាក្សា Feedback ពីអង្គភាពផ្ទៃក្នុង ដើម្បីកែលម្អការអនុវត្តឆ្នាំក្រោយ។

៦. ការបណ្តុះបណ្តាល និងលើកទឹកចិត្តបុគ្គលិក

- រៀបចំវគ្គបណ្តុះបណ្តាលផ្នែកហិរញ្ញវត្ថុ និងការគ្រប់គ្រងថវិកាសម្រាប់អ្នកគ្រប់គ្រងផ្នែកនីមួយៗ។
- បង្កើតប្រព័ន្ធរង្វាន់ជំនាញ ឬការលើកទឹកចិត្តសម្រាប់ការអនុវត្តន៍ផែនការដោយជោគជ័យ។

**៣.២.៣ គុណសម្បត្តិ និងគុណវិបត្តិ នៃការធ្វើផែនការ ក្នុងក្រុមហ៊ុន**

ការធ្វើផែនការ គឺជាផ្នែកមួយនៃដំណើរការគ្រប់គ្រងដែលសំខាន់ណាស់សម្រាប់ស្ថាប័ន ឬក្រុមហ៊ុន ដើម្បីសម្រេចបាននូវគោលដៅរយៈខ្លី និងវែង។ ប៉ុន្តែការធ្វើផែនការក៏មានទាំងគុណសម្បត្តិ និងគុណវិបត្តិផងដែរ។

គុណសម្បត្តិ (Advantages) នៃការធ្វើផែនការ

១. កំណត់ទិសដៅច្បាស់លាស់សម្រាប់អាជីវកម្ម៖ ផែនការជួយក្រុមហ៊ុនដឹងថាត្រូវទៅណា និងតើត្រូវធ្វើអ្វីដើម្បីសម្រេចគោលដៅ។

២. ជួយក្នុងការទុកចិត្ត និងសម្រេចចិត្តបានល្អ៖ ដោយមានផែនការ បុគ្គលិក និងអ្នកគ្រប់គ្រងអាចសម្រេចចិត្តបានល្អ ពីការប្រើធនធាន និងវិនិយោគ។

៣. ជួយក្នុងការចាត់ចែងធនធាន (resource allocation)៖ បែងចែកថវិកា បុគ្គលិក និងសម្ភារៈតាមលំដាប់អាទិភាពដែលអាចគ្រប់គ្រងបាន។

៤. បង្កើនប្រសិទ្ធភាពនិងផលិតភាព៖ ការធ្វើផែនការជំរុញឱ្យការងារធ្វើតាមគោលបំណង បន្ថយការបាត់បង់ពេល និងថវិកាឥតចាំបាច់។

៥. ជាស្នាដៃសំខាន់សម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ៖ អាចប្រៀបធៀបរវាងអ្វីដែលបានគ្រោង (Planned) និងអ្វីដែលបានធ្វើ (Actual) ដើម្បីកែសម្រួល។

៦. ជួយការទំនាក់ទំនងក្នុងក្រុម៖ ធ្វើឱ្យសមាជិកមានការយល់ចូលគ្នា អំពីគោលដៅ និងតួនាទីរបស់ខ្លួនក្នុងក្រុមហ៊ុន។

គុណវិបត្តិ (Disadvantages) នៃការធ្វើផែនការ

១. ចំណាយពេលវេលា និងថវិកាច្រើន៖ ដំណើរការធ្វើផែនការជាពិសេសផែនការធំនឹងចំណាយធនធានច្រើន។

២. អាចនឹងមិនអាចព្យាករណ៍អនាគតបានត្រឹមត្រូវ៖ បញ្ហាអាកាសធាតុទីផ្សារ សេដ្ឋកិច្ច ឬវិបត្តិធម្មជាតិអាចធ្វើឱ្យផែនការមិនអនុវត្តបានពិតប្រាកដ។

៣. បន្ថយភាពបត់បែន (Rigidity)ប្រសិនបើផែនការមិនអាចបត់បែនបានទៅតាមស្ថានភាពថ្មី អាចបង្កការបាត់បង់ឱកាស។

៤. អាចបង្កជម្លោះក្នុងក្រុម៖ ប្រសិនបើមនុស្សម្នាក់ៗមិនយល់ចំពោះផែនការនោះ និងគ្មានភាពក្នុងការសម្រេចចិត្តត្រឹមត្រូវ។

៥. បង្កការពឹងផ្អែកលើទិន្នន័យចាស់ៗ៖ អាចបណ្តាលឱ្យផែនការមិនសមស្របបើប្រើទិន្នន័យអតីតកាលដែលមិនអាចអនុវត្តបាននៅស្ថានភាពបច្ចុប្បន្ន។

ជារួមមកការធ្វើផែនការជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់គ្រប់គ្រង និងអភិវឌ្ឍអាជីវកម្ម ប៉ុន្តែវាត្រូវបានអនុវត្តដោយយល់ដឹង និងមានភាពបត់បែន។ ក្រុមហ៊ុនគួរតែធ្វើការត្រួតពិនិត្យផែនការជាប្រចាំ និងធ្វើកែសម្រួលពេលមានបម្លែងនានា។

## ៣.៣ យុទ្ធសាស្ត្រក្នុងការបង្កើនចំណូលនិងគ្រប់គ្រងចំណាយមានឱ្យប្រសិទ្ធិភាព

### ៣.៣.១ ការបង្កើនចំណូលរបស់ក្រុមហ៊ុន

ចំណូលសំដៅលើប្រាក់ចំណូលសរុបដែលបង្កើតដោយក្រុមហ៊ុនពីសកម្មភាពអាជីវកម្មស្នូលរបស់ខ្លួនដូចជាការលក់ទំនិញ ឬសេវាកម្ម ក្នុងរយៈពេលជាក់លាក់មួយ។ វាតំណាងឱ្យចំនួនប្រាក់ដែលទទួលបានមុនពេលកាត់ការចំណាយ ពន្ធ និងការចំណាយផ្សេងៗទៀត។ ចំណូល គឺជារង្វាស់សំខាន់សម្រាប់វាយតម្លៃដំណើរការអាជីវកម្ម និន្នាការកំណើន និងប្រាក់ចំណេញ ដែលមានឥទ្ធិពលលើការសម្រេចចិត្តជាយុទ្ធសាស្ត្រ និងការវាយតម្លៃសុខភាពហិរញ្ញវត្ថុ។

ចំណូល គឺជាការហូរចូលនូវសាច់ប្រាក់ ឬកើនទ្រព្យសកម្ម ឬសំណងនៃបំណុលនៅក្នុងកំឡុងពេលណាមួយទទួលបានពីការផលិតទំនិញ ផ្គត់ផ្គង់សេវាកម្ម ឬសកម្មភាពផ្សេងៗ ដែលទាក់ទងនឹងប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយចំណូលអាចជាថ្លៃទំនិញដែលបានលក់តាមរយៈការផ្តល់សេវាកម្មនៅក្នុងកំឡុងពេលនៃខួបគណនេយ្យ

* ប្រភេទចំណូលទាំង ៨៖

- ប្រាក់បៀវត្សការងារ
- ចំណូលពីការចំណេញ
- ចំណូលពីការប្រាក់
- ចំណូលពី Royalty
- ចំណូលពីភាគលាភ
- ចំណូលពីថ្លៃជួល
- ចំណូលពីទ្រព្យឡើងថ្លៃ (ផ្ទះ ដី ភាគហ៊ុន)
- ចំណូលបែប Residual។

ការមានចំណូលពីប្រភពជាច្រើនជាមូលដ្ឋានសម្រាប់ការពង្រឹងស្ថេរភាពហិរញ្ញវត្ថុ និងអាចផ្តល់សុវត្ថិភាពបានខ្ពស់។ នៅក្នុងសង្គមបច្ចុប្បន្នមានការប្រកួតប្រជែងខ្លាំង ការពឹងផ្អែកលើប្រភពចំណូលតែមួយអាចបង្កហានិភ័យផ្នែកសេដ្ឋកិច្ច។

ខាងក្រោមនេះជាប្រភពចំណូលសំខាន់ៗមួយចំនួនរបស់ក្រុមហ៊ុន អិន ស៊ី អិច៖

១. លក់ម៉ូតូ Honda ថ្មី

- ជាផ្នែកចម្បងនៃចំណូលក្រុមហ៊ុន
- ម៉ូតូ Honda មានតម្លៃសមរម្យ និងគុណភាពខ្ពស់
- ផលិតផលពេញនិយមក្នុងប្រទេសកម្ពុជា
- ក្រុមហ៊ុនមានបណ្តាញភ្នាក់ងារ និងតំណាងចែកចាយគ្រប់ខេត្ត

២. លក់គ្រឿងបន្លាស់ (Spare Parts)

- គ្រឿងបន្លាស់ដើមរបស់ Honda
- ជាចំណូលមិនអាស្រ័យលើការលក់ម៉ូតូថ្មី
- ផ្តល់ជូនគ្រឿងម៉ាស៊ីន, សំបកកង់, អាគុយ, បំភ្លឺ...

៣. សេវាកម្មជួសជុល និងថែទាំ (Maintenance & Repair Services)

- សេវាកម្មបច្ចេកទេសស្តង់ដារ Honda
- ជួសជុលម៉ាស៊ីន, កង់, ប្រព័ន្ធភ្លើង
- ចំណូលចេញពីថ្លៃសេវា និងគ្រឿងផ្សេងៗ

៤. ផ្នែកបណ្តុះបណ្តាលបច្ចេកទេស (Technical Training)

- ក្រុមហ៊ុនធ្វើបណ្តុះបណ្តាលផ្ទាល់ឲ្យជាង
- ផ្តល់វគ្គបណ្តុះបណ្តាលទៅឲ្យភ្នាក់ងារ (ជារបៀបគាំទ្រអាជីវកម្ម)

- ចំណូលជារូបវត្តសិក្សា ឬសេវាបណ្តុះបណ្តាល

៥. អាជីវកម្មនាំចូលនាំចេញ (Import-Export Activities)

- ក្រុមហ៊ុនមានសិទ្ធិនាំចូលម៉ូតូ និងគ្រឿងបន្លាស់
- ការនាំចូលផ្ទាល់ធ្វើឲសន្សិភាពថ្លៃ និងកំណត់គុណភាព
- ប្រសិនបើមានសាខាផ្សេងបន្ថែមអាចនាំចេញទៅបរទេស

៦. ចំណូលពីការវិនិយោគផ្សេងៗ

- វិនិយោគក្នុងអចលនទ្រព្យ (ដី សណ្ឋាគារ ភោជនីយដ្ឋាន)
- ជាគម្រោងបន្ថែមក្រៅពីម៉ូតូ
- ទទួលបានចំណូលពីការជួល និងលក់អចលនវត្ថុ

**៣.៣.២ ការគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុន**

ការគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុន N.C.X គឺមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការរក្សាប្រសិទ្ធភាពនៃការប្រតិបត្តិ និងបង្កើនប្រាក់ចំណេញ។

១. គ្រប់គ្រងបុគ្គលិក និងការបណ្តុះបណ្តាល

- កាត់បន្ថយបុគ្គលិកបើចាំបាច់ (លើផ្នែកដែលមិនទាន់មានប្រសិទ្ធភាព)
- ផ្តល់ការបណ្តុះបណ្តាលបុគ្គលិក ដើម្បីធ្វើការងារបានច្រើន និងមានគុណភាព
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាដើម្បីជំនួសការងារមនុស្សនៅពេលអាចធ្វើបាន

២. អភិវឌ្ឍផលិតភាព (Productivity)

- រៀបចំពេលវេលាដោយមានប្រសិទ្ធភាព
- ដំឡើងឧបករណ៍ឆ្លាតវៃ ឬប្រព័ន្ធអូតូម៉ាតក្នុងបញ្ជាក់សម្ភារៈ/ផលិតផល
- ចំណាយលើការកែលម្អគុណភាពឧបករណ៍ ដើម្បីអោយប្រើបានយូរជាងមុន

៣. ការគ្រប់គ្រងសារពើភ័ណ្ឌ (Inventory Management)

- បន្ថយការទុកសម្ភារៈឱ្យលើសកំណត់
- សម្របសម្រួលការបញ្ជាទិញសម្ភារៈឱ្យត្រឹមត្រូវ និងជៀសវាងការប៉ាន់ស្មានខុស

៤. ចំណាយលើទីផ្សារ និងផ្សព្វផ្សាយ

- ប្រើការផ្សព្វផ្សាយតាមអ៊ីនធឺណិត (Digital Marketing) ជំនួសបែបប្រពៃណី
- សហការជាមួយក្រុមហ៊ុនដៃគូរ ដើម្បីចែកចាយ និងកាត់បន្ថយតម្លៃផ្សព្វផ្សាយ

៥. គ្រប់គ្រងសេវាកម្មក្រោយការលក់

- បង្កើតប្រព័ន្ធសេវាកម្មក្រោយការលក់ដើម្បីរក្សាភាពជឿជាក់
- បង្ហាញថ្លៃសេវាជាសាច់លុយ ឬតម្លៃដាក់លាក់ ដើម្បីជៀសវាងការចំណាយខុសបំណង
- ប្រើគ្រឿងបន្លាស់មានគុណភាពខ្ពស់ ដើម្បីបន្ថយការជួសជុលជាបន្តបន្ទាប់

៦. ការត្រួតពិនិត្យ និងវាយតម្លៃបច្ចេកទេសជាប្រចាំ

- ត្រួតពិនិត្យកម្រាស់ចំណាយសប្តាហ៍ ខែ ឆ្នាំ
- ប្រើ Key Performance Indicators (KPIs) ដើម្បីវាស់ថ្លៃការចំណាយ

- រៀបចំផែនការចំណាយប្រចាំឆ្នាំ ដើម្បីឱ្យការអភិវឌ្ឍន៍អាជីវកម្មប្រកបដោយរលូន

៧. ការចងសម្ព័ន្ធជាមួយដៃគូផ្គត់ផ្គង់

- ចរចារថ្លៃជាមួយអ្នកផ្គត់ផ្គង់ ដើម្បីបានតម្លៃសមរម្យ
- បង្កើតកិច្ចសន្យាទិញជាយូរអង្វែង ដើម្បីបានការបញ្ចុះតម្លៃ
- ជ្រើសរើសដៃគូរស្ថិតស្ថេរ មានគុណភាព និងសេវាកម្មល្អ

**៣.៣.៣ ប្រភពចំណូលចំណាយសំខាន់ៗរបស់ក្រុមហ៊ុនអិច ស៊ី អិច**

**ក.ប្រភពចំណូល**

ការលក់ផលិតផល៖ ប្រភពចំណូលពីការលក់ផលិតផលមានបែងចែកជា ៣ ផលិតផលទៀតគឺ៖ ចំណូលបានពីការលក់ ម៉ូតូចង្កឺះលេខ ចំណូលបានពីការលក់ម៉ូតូអូតូ និងចំណូលបានពីការលក់ម៉ូតូអាំប្រាយ៉ា។ ចំណូលដែលបានពីការលក់ផលិតផលទាំង៣ខាងលើនេះ គឺជាចំណូលគោល ចំណូលសំខាន់បំផុត សម្រាប់ជីវិតអាជីវកម្មរបស់ក្រុមហ៊ុនទាំងមូល។ ហេតុដែលហ៊ាននិយាយដូច្នេះ ព្រោះសកម្មភាពអាជីវកម្ម សំខាន់របស់ក្រុមហ៊ុន អិន ស៊ី អិច គឺជាក្រុមហ៊ុនបែបពាណិជ្ជកម្មរកស៊ីលក់ម៉ូតូ រថយន្ត និងគ្រឿងចក្រជា ច្រើនប្រភេទទៀត។ ចំណូលដែលបានមកពីការលក់ផ្នែកផលិតផលនេះមានអត្រាកើនឡើងពីមួយឆ្នាំទៅ មួយឆ្នាំបង្ហាញឱ្យឃើញថាក្រុមហ៊ុនមានគោលការណ៍ច្បាស់លាស់ក្នុងការគ្រប់គ្រងចំណូលប្រកបដោយ ស្ថេរភាពហើយរក្សាបាននូវទស្សនៈជាសកលដោយលះបង់គ្រប់យ៉ាង ដើម្បីឱ្យផលិតផលមានគុណភាព ខ្ពស់ឈានមុខគេព្រមទាំងមានតម្លៃសមរម្យសម្រាប់បំពេញតម្រូវការរបស់អតិថិជននៅទូទាំងប្រទេសកម្ពុជា ក៏ដូចជាទូទាំងសកលលោក។ ជាក់ស្តែងប្រាក់ចំណូលដែលបានមកពីទីផ្សារលក់ផលិតផលម៉ូតូនេះក្នុងឆ្នាំ ២០២០ មានចំនួនប្រមាណជាង ១លាន១៤៨ពាន់ដុល្លាអាមេរិក (នេះបើតាមការបង្ហើបឱ្យដឹងតិចតួចពី សំណាក់គណនេយ្យករក្រុមហ៊ុន) ហើយប្រាក់ចំណូលនេះត្រូវបានរំពឹងថានឹងកើនឡើងប្រមាណ៥.៩៦% នៅចន្លោះ ឆ្នាំ២០២២ ដល់ ២០២៦។ តម្លៃឯកតាដែលក្រុមហ៊ុនបានរំពឹងទុកក្នុងឆ្នាំ២០២៦ ចំពោះម៉ូតូ Hongda Dream C125 គឺមានតម្លៃ២,៩៧៤ដុល្លារក្នុងមួយគ្រឿង។ ហេតុផលដែលធ្វើឱ្យក្រុមហ៊ុនរំពឹងខ្ពស់លើ ការកើនឡើងនូវប្រាក់ចំណូលបែបនេះ ព្រោះផលិតផលរបស់ក្រុមហ៊ុន អិន ស៊ី អិច គ្រប់ប្រភេទសុទ្ធតែ មានលក្ខណៈពិសេសដែលអាចទាក់ទាញចិត្តអតិថិជនរបស់ខ្លួន។

លក្ខណៈពិសេស និងអត្ថប្រយោជន៍ទាំងនោះរួមមានដូចជា៖

**ម៉ូតូចង្កឺះលេខ៖** វាគឺជាប្រភេទម៉ូតូមួយដែលមានការរចនាម៉ូតឡើងចេញជារូបរាងយ៉ាងប្រណិតទៅ លើតែមសងខាងផ្ទៃមុខ និង ផ្ទៃចំហៀងក្រោយរចនាម៉ូត 3D ផុសលេចធ្លោរលេចឡើងដោយសរសៃរមាស ។ ប្រអប់សោរបំពាក់ដោយសន្ទុះការពារសុវត្ថិភាព ២ ជាន់ កុងតាក់បិទបើកភ្លើង ៣ តង់ ងាយស្រួលបើកបរ។ ជាពិសេសទៅទៀតវានៅតែរក្សាបាននូវជាមួយកម្លាំងម៉ាស៊ីន Econo Power 4តង់ 125cc មានថាមពលខ្លាំង សន្សំសំចៃប្រេងជាមួយ និងរយៈពេលប្តូរប្រេងម៉ាស៊ីនហូតដល់ 6,000 គីឡូម៉ែតយូរជាងម៉ាស៊ីនផ្សេងៗទ្វេដង។ ចំណែកដំណើរការរបស់ម៉ាស៊ីនវិញ គឺស្ងាត់ល្អ ព្រោះបំពាក់ដោយប្រព័ន្ធ Silent Chain ដែលផ្តល់អាយុកាល ប្រើប្រាស់បានយូរហើយជួយសន្សំសំចៃថវិកា ស៊ីសាំងតិចធន់ទៅនឹងស្ថានភាពផ្លូវពិបាកៗ ។

**ម៉ូតូអូតូ៖** មានការរចនាម៉ូតជាប្រភេទតែមក្រដាសភ្លើងមុខរចនាបញ្ចូលគ្នាជាមួយនឹង Super 3D Emboss ។ Design ស្ទីលថ្មីទាក់ភ្នែករួមជាមួយបច្ចេកទេសឆ្លាតវៃ "ESP" ជួយឱ្យកម្លាំងម៉ាស៊ីន ស្ទុះខ្លាំង ហើយវាមាន

ប្រព័ន្ធសន្សំសំចៃសាំង (Idling Stop) ដែលជួយកាត់បន្ថយការចំណាយរបស់អតិថិជនបានមួយកម្រិតថែមទៀត។ អ្វីដែលពិសេសថែមទៀតនោះវាមានកុងទ័រឌីជីថលដែលបង្ហាញយ៉ាងច្បាស់ពីល្បឿនម៉ូតូ ចម្ងាយផ្លូវដែលម៉ាស៊ីនបានរត់ និងកម្រិតប្រេងឥន្ធនៈដែលមានជាដើម។ ក្នុងនោះដែរវាមានបង្ហាញអំពីកម្តៅម៉ាស៊ីនធ្វើឱ្យយើងងាយស្រួលក្នុងការធ្វើដំណើរប្រកបដោយទំនុកចិត្ត។

**ម៉ូតូអាំប្រាយ៉ា៖** មានការរចនាម៉ូតបែបឌីណាមិចវាមើលទៅមានលក្ខណៈបែបស្ព័រដ៏ល្អប្រណិត នៅគ្រប់ទិសទី និងបង្កើនចលនាល្បឿនជាមួយនឹងម៉ាស៊ីនកម្លាំង 150cc DOH 4 តង់បញ្ចុះកម្តៅដោយទឹកកាត់បន្ថយកម្លាំងកកិត កាត់បន្ថយការអូស រក្សាលំនឹងជួយការពារការកន្រ្តាក់ព្រមទាំងកាត់បន្ថយការរលាស់ខាងក្រោយពីការធ្វើការរបស់អាំប្រាយ៉ាពេលដូរលេខភ្លាមៗហើយប្រលែងអាំប្រាយ៉ា។ ចង្កៀងមុខ LED មានការរចនាម៉ូតដ៏មុតស្រួច លិចផ្លោ ពន្លឺភ្លើងរួមបញ្ចូលគ្នា ភ្លឺច្បាស់គ្រប់ស្ថានភាពផ្លូវហើយប្រព័ន្ធហ្វ្រាំង ABS ទំនើបមានបន្ទះហ្វ្រាំងមុខ និងក្រោយទំហំធំ បែប Wave Disc ជំនួយដល់ការបញ្ឈប់ល្បឿនបានយ៉ាងជឿជាក់ជាពិសេសប្រព័ន្ធភ្លើង EMERGENCY STOP SIGNAL (ESS) ផ្តល់ដំណឹងដោយភ្លើងភ្លឺភ្លែតៗនៅលើស៊ីញ៉ូមុខ និងស៊ីញ៉ូក្រោយដោយស្វ័យប្រវត្តិនៅពេលចាប់ហ្វ្រាំងបន្ទាន់ ឬឈប់ភ្លាមៗ។

២.ប្រភពមកពីសេវាជួសជុល

សេវាកម្មជួលជុលរបស់ក្រុមហ៊ុន អិន ស៊ី អិច ដែលផ្តល់ជូនអតិថិជនខ្លួន គឺជាផ្នែកមួយនៃប្រភពចំណូលរបស់ក្រុមហ៊ុន។ ចំពោះអតិថិជន ដើម្បីទទួលបាននូវសុវត្ថិភាព ចំណេញថវិកា ម៉ូតូមានដំណើរការល្អបញ្ចៀសបានពីការខូចខាតផ្សេងៗ ដើម្បីបរិស្ថានស្អាត និងដើម្បីប្រាកដថាគ្រប់ផ្នែកទាំងអស់របស់ម៉ូតូមានភាពប្រក្រតី។ ចាំបាច់ណាស់លោកអ្នកត្រូវធ្វើតំហែទាំម៉ូតូឱ្យបានត្រឹមត្រូវ។ ផ្នែកជួសជុលម៉ូតូក្រុមហ៊ុន អិន ស៊ី អិច មានគ្រឿងបន្លាស់សុទ្ធជាមួយនឹងជាងដែលមានជំនាញក្នុងការវិភាគបញ្ហាយ៉ាងច្បាស់លាស់ព្រមទាំងផ្តល់ជូនលោកអ្នកនូវការធ្វើតំហែទាំ និងជួសជុលក្នុងរយៈពេលមួយសមស្រប និងតម្លៃសមរម្យដែលអាចទទួលយកបាន។

ចំណូលពីសេវាកម្មរបស់ អិន ស៊ី អិច បែងចែកជា ៣ ប្រភេទធំៗ៖

• ការថែទាំតាមកាលកំណត់ (ការត្រួតពិនិត្យ និងផ្លាស់ប្តូរប្រេងម៉ាស៊ីន ត្រួតពិនិត្យដំណើរការម៉ាស៊ីន ប្រព័ន្ធសម្រួលរលាក់ កកិត និងប្រព័ន្ធភ្លើង)

ការថែទាំតាមកាលកំណត់ដែលត្រូវបង្កើតឡើងដើម្បីថែរក្សាយានយន្ត និងទោចក្រយានយន្តឱ្យរក្សានូវដំណើរការល្អ និងសន្សំសំចៃប្រេងបានល្អ។ ទោចក្រយានយន្តមួយគ្រឿង ត្រូវបានផ្គុំឡើងពីគ្រឿងបន្លាស់ផ្សេងៗដ៏ច្រើនអនេកដែលគ្រឿងបន្លាស់ទាំងនោះនឹងមានការសឹករិចរិលចុះអន់ថយ ឬច្រិះចាប់ដែលបណ្តាលឱ្យដំណើរការរបស់វាខ្សោយទៅៗអាស្រ័យតាមលក្ខខណ្ឌ និងរយៈពេលនៃការប្រើប្រាស់។ បង្គុំគ្រឿងបន្លាស់ផ្សេងៗ ត្រូវមានការថយចុះគុណភាពចាំបាច់ត្រូវធ្វើការថែទាំតាមដំណាក់កាលធ្វើការសារ៉េ ឬផ្លាស់ប្តូរដោយអនុវត្តតាមតារាងថែទាំតាមលក្ខខណ្ឌបច្ចេកទេសកំណត់ពីរោងចក្រ ដើម្បីចៀសវាងការខូចខាតផ្សេងៗ និងដើម្បីមានទំនុកចិត្តក្នុងការបើកបរប្រកបដោយសុវត្ថិភាព។

អត្ថប្រយោជន៍នៃការថែទាំរថយន្តតាមកាលកំណត់៖ ការពារបាននូវការខាតបង់ធ្ងន់ធ្ងរផ្សេងៗ ធ្វើឱ្យម៉ូតូស៊ីប្រេងតិចនិងសន្សំសំចៃខ្ពស់ ការពារបរិស្ថាន ឱ្យបានស្អាត ផ្តល់សុវត្ថិភាពខ្ពស់ និងរក្សាគុណភាពយាន

យន្តឱ្យនៅល្អប្រសើរ រក្សាអាយុកាលរថយន្តឱ្យប្រើប្រាស់បានយូរផ្តល់ជូនការជានាលើរថយន្តថ្មីឱ្យរីករាយក្នុងការបើកបរ។ គ្រឿងបន្លាស់នៃការថែទាំតាមកាលកំណត់៖ ប្រេងម៉ាស៊ីន តម្រង់ប្រេងម៉ាស៊ីន អ៊ែរម៉ាស៊ីន ទឹកស្អំម៉ាស៊ីន តម្រង់ប្រេង ប្រេងហ្វ្រាំង ប្រេងប្រអប់លេខ ប្រេងបូមចង្កូត ។ល។

មុខងាររបស់គ្រឿងបន្លាស់នីមួយៗនៃការថែទាំតាមកាលកំណត់៖

- ប្រេងម៉ាស៊ីនប្រើសម្រាប់ រំអិល សម្អាត និងការពារចេះ

- តម្រង់ប្រេង ត្រូវបានប្រើជាវត្ថុចម្លោះ និងធ្វើឱ្យម៉ាស៊ីនដំណើរការដោយរលូននៅក្នុងប្រព័ន្ធម៉ាស៊ីន ហើយវាក៏អាចយកសារជាតុកខ្វក់ចេញពីប្រេងម៉ាស៊ីនបានផងដែរ។

- អ៊ែរម៉ាស៊ីន ត្រូវបានប្រើដើម្បីព្រោះខ្យល់ដើម្បីសម្អាត មុនពេលវាចូលស៊ីឡាំងម៉ាស៊ីនវាអាចការពារភាពកខ្វក់ ឬធូលីចូលក្នុងម៉ាស៊ីន។

- ទឹកស្អំម៉ាស៊ីន គឺត្រូវបានប្រើប្រាស់ដើម្បីបញ្ចុះកម្តៅម៉ាស៊ីនខណៈវាដំណើរការ ហើយវាការពារការឡើងកម្តៅខ្លាំងដែលនាំឱ្យខូចម៉ាស៊ីន។

- ការជួសជុលទូទៅ

ការជួសជុលទូទៅគឺជាប្រភេទនៃការជួសជុល ឬដំណើរការដែលមិនទាក់ទងនឹងការថែទាំតាមដំណាក់កាល ដោយសារស្ថានភាពយានយន្តដែលកំពុងដំណើរការមិនប្រក្រតី ឬគ្រឿងបន្លាស់ដែលបំពាក់សឹករិចរិល។ ការជួសជុលទូទៅ គឺជាដំណើរការនៃការផ្លាស់ប្តូរគ្រឿងបន្លាស់ ឬការកែតម្រូវក្នុងគោលបំណងនៃការរក្សាយានយន្តឱ្យទៅរកស្ថានភាពដើមវិញ។ ដើម្បីឱ្យការជួសជុលទូទៅទទួលបានលទ្ធផលល្អម្ចាស់រថយន្ត ឬម្ចាស់ទោចក្រយានយន្តត្រូវតែយកយានយន្តហុងដារបស់លោកអ្នកទៅយានដ្ឋាន ហុងដា ដើម្បីទទួលបានការផ្លាស់ប្តូរគ្រឿងបន្លាស់ជាមួយជាងហុងដាដែលមានវិជ្ជាជីវៈត្រឹមត្រូវ។

អត្ថប្រយោជន៍នៃការជួសជុលទូទៅ៖ ដំណើរការល្អ មានរូបរាងល្អស្រស់ស្អាត បើកបរមានការសន្សំសំចៃល្អ បើកបរប្រកបដោយសុវត្ថិភាព បើកបរប្រកបដោយផាសុខភាព លក់បន្តបានតម្លៃថ្លៃប្រើប្រាស់បានយូរអង្វែង។

គ្រឿងបន្លាស់ការជួសជុលទូទៅរួមមាន៖ ប្រព័ន្ធម៉ាស៊ីន ប្រព័ន្ធគ្រឿងក្រោម ប្រព័ន្ធម៉ាស៊ីនត្រជាក់ ប្រព័ន្ធអូសទាញ ប្រព័ន្ធម៉ែត្រចង្កូត ។ល។

មុខងារនៃគ្រឿងបន្លាស់ការជួលជុលទូទៅ៖

- ប្រព័ន្ធម៉ាស៊ីន គឺជាកន្លែងដែលមានថាមពល ហើយបង្កើតថាមពលដល់ប្រព័ន្ធដំរុញក្នុងគោលបំណង ធ្វើឱ្យយានយន្តដំណើរការបានរលូននិងមានផាសុកភាព។

- ប្រព័ន្ធគ្រឿងក្រោម ប្រើសម្រាប់ជួយយានយន្តឱ្យប្រសើរឡើងក្នុងការជិះនិងស្ថេរភាពដៃចង្កូត។

- ប្រព័ន្ធម៉ាស៊ីនត្រជាក់ គឺជាគ្រឿងត្រជាក់ដើម្បីបង្កើតសីតុណ្ហភាពត្រជាក់នៅក្នុងចន្លោះកាប៊ីន និងរក្សាខ្យល់អាកាសបរិសុទ្ធក្នុងលំហដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកបើកបរ និងអ្នកដំណើរ។

- ប្រព័ន្ធអគ្គិសនីមានសារៈសំខាន់ខ្លាំងណាស់សម្រាប់យានយន្តវាត្រូវបានគេប្រើដើម្បីផ្គត់ផ្គង់ប្រភពថាមពលនៅគ្រប់តំបន់វាចាំបាច់ណាស់ ដើម្បីឱ្យរថយន្តដំណើរការរលូន និងមានផាសុកភាព។ ប្រសិនបើគ្មានប្រព័ន្ធអគ្គិសនីទេយានយន្ត និងមិនអាចដំណើរការបានទេ។

- ការជួសជុលកម្រិតធ្ងន់ធ្ងរ

ការជួសជុលកម្រិតធ្ងន់ធ្ងរ គឺជាប្រភេទនៃការជួសជុលសម្រាប់យានយន្តណាដែលលែងដំណើរការ ឬគ្រឿងបន្លាស់ដែលបំពាក់នៅយានយន្តនោះបានខូច។

គ្រឿងបន្លាស់នៃផ្នែកតួរថយន្ត៖ ចង្កៀង មុខ ស្តុបក្រោយ ទ្វារមុខ ទ្វារក្រោយ បូមមុខនិងបូមក្រោយ កាងមុខនិងកាងក្រោយ គម្របម៉ាស៊ីន ត្រគៀក ដំបូល ស៊ុម តួរថយន្ត។ ល។

មុខងារគ្រឿងបន្លាស់នៃការជួសជុលកម្រិតធ្ងន់ធ្ងរ៖

- គ្រឿងបន្លាស់នៃផ្នែកតួរថយន្ត គឺត្រូវបានរចនាដើម្បីឱ្យយានយន្ត ស្រស់ស្អាត (រូបរាងខាងក្រៅ និងទាក់ទាញអារម្មណ៍)

- ចង្កៀងមុខ គឺប្រៀបដូចជាកែវភ្នែករបស់មនុស្សវាបង្ហាញពីរូបរាងរបស់យានយន្ត នៅកំឡុងពេលដែលងងឹត ដើម្បីផ្តល់ពន្លឺគ្រប់គ្រាន់សម្រាប់អ្នកបើកបរកំឡុងពេលបើកបរ។

- ស្តុបក្រោយ គឺជាកន្លែងដែលមើលទៅស្រស់ស្អាត និងលេចធ្លោសម្រាប់យានយន្តទាំងអស់ ហើយវាសម្រាប់បង្ហាញប្រាប់ពីព័ត៌មានយានយន្តនៅពេលដែលត្រូវឈប់ ឬបត់។

- ទ្វារមុខ និងទ្វារក្រោយ៖ ទ្វារ គឺដូចជាជញ្ជាំងដែលការពារអ្នកបើកបរ និងអ្នកដំណើរនៅក្នុងលំហកាប៊ីនហើយវាក៏ជាច្រកសម្រាប់មនុស្សចេញនិងចូលយានយន្តផងដែរ។

- តួរថយន្ត៖ តួរត្រូវបានបង្កើតនិងរចនាឡើងដើម្បីទ្រទ្រង់រក្សាតួរថយន្តឱ្យមានភាពរឹងមាំ និងបើកបរប្រកបដោយផាសុកភាព។ វាត្រូវបានគេរចនាឡើងដើម្បីកាត់បន្ថយផលប៉ះពាល់ពេលមានគ្រោះថ្នាក់កើតឡើង។

**ខ.ប្រភពចំណាយ**

- **ចំណាយប្រតិបត្តិការ**

ជាទូទៅ រាល់ចំណាយដែលទាក់ទង និងការស្នើទិញសម្ភារៈដើម្បីយកទៅប្រើប្រាស់នៅក្នុងចំណាយប្រតិបត្តិការផ្នែកនីមួយៗតម្រូវឱ្យធ្វើលិខិតស្នើសុំទៅកាន់ផ្នែករដ្ឋបាល បន្ទាប់មកផ្នែករដ្ឋបាលត្រូវត្រួតពិនិត្យទៅលើពាក្យស្នើសុំទិញនូវសម្ភារនោះថា តើប្រធានផ្នែករបស់គាត់បានយល់ព្រម ដើម្បីឱ្យគាត់ដាក់សំណើរទៅលើ ចំណាយនោះហើយឬនៅ។ បន្ទាប់ពីផ្នែករដ្ឋបាលបានពិនិត្យមើលលើសំណើរនោះមានការអនុម័តនិងយល់ព្រមគ្រប់លក្ខខណ្ឌទាំងអស់នោះហើយផ្នែករដ្ឋបាលក៏បញ្ជូនសំណើរស្នើសុំនោះមកខាងផ្នែកហិរញ្ញវត្ថុដើម្បីឱ្យប្រធានក្រុមហ៊ុនត្រួតពិនិត្យ និងអនុញ្ញាតទៅលើសំណើរនោះ។ នៅពេលប្រធានក្រុមហ៊ុនយល់ព្រមហើយផ្នែកបញ្ជាទិញ ក៏បានរៀបចំទាក់ទងទៅខាងអ្នកផ្គត់ផ្គង់នូវសម្ភារៈដែលយើងបានដាក់សំណើរស្នើសុំនោះ។ ក្រោយពីបានធ្វើការបញ្ជាទិញចប់សព្វគ្រប់អស់អ្នកផ្គត់ផ្គង់ក៏បានចេញវិក័យបត្រឱ្យមកផ្នែកបញ្ជាទិញហើយក៏បានប្រគល់វិក័យបត្រឱ្យមកផ្នែកហិរញ្ញវត្ថុនៅពេលផ្នែកហិរញ្ញវត្ថុពិនិត្យនូវមុខទំនិញសម្ភារៈគ្រប់អស់ហើយ ក៏បានបញ្ជូននូវវិក័យបត្រនោះឱ្យទៅប្រធានក្រុមហ៊ុនដើម្បីទូទាត់លើថ្លៃសម្ភារៈទាំងអស់នោះ។

- **ចំណាយធំក្នុងក្រុមហ៊ុន**

គ្រឿងបន្លាស់សុទ្ធ អិន ស៊ី អិច ត្រូវបានសិក្សាស្រាវជ្រាវ និងផលិតឡើងដោយក្រុមវិស្វករហុងដាក្រោមការគ្រប់គ្រងគុណភាពដោយក្រុមហ៊ុន អិន ស៊ី អិច មូទ័រ ជប៉ុន រាល់គ្រឿងបន្លាស់សុទ្ធហុងដា មានលេខកូដគ្រឿងបន្លាស់ និងឈ្មោះគ្រឿងបន្លាស់បែងចែកទៅតាមប្រភេទប្រវែងខ្នាត និងមុខនាទីគ្រឿងបន្លាស់នីមួយៗយ៉ាងច្បាស់លាស់ប្រកបដោយ គុណភាព សុវត្ថិភាពជាចម្បងមិនមានការកែច្នៃដើម្បីប្រើប្រាស់ធន់នឹងបានយូរអង្វែង សន្សំសំចៃថវិកាជួសជុល គ្រឿងបន្លាស់សុទ្ធរបស់ម៉ូតូហុងដាមានដូចជា៖

១. ប្រេងម៉ាស៊ីនសំរាប់ម៉ូតូប្រភេទចង្កឹះលេខ អូតូ និងប្រេងកាឡេ

២. គ្រឿងតំហែទាំមានដូចជា៖ ប៊ូស៊ី សំបុកអ៊ែរ ច្រវ៉ាក់ពីញ៉ុង ខ្សែពាន ស្បែកហ្វ្រាំង សំបកពោះវៀន, អាគុយ ,ទឹកបញ្ចុះកំដៅ ។ល។




ប៊ូស៊ី




ប្រេងម៉ាស៊ីន



សំបុកអ៊ែរ

ស្បែកហ្វ្រាំង



# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤

# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

ក្រុមហ៊ុន អិន ស៊ី អិច គឺជាក្រុមហ៊ុនដែលផលិត រថយន្ត និងម៉ូតូ ដើម្បីឱ្យប្រធានបទ ″ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុ″ នេះរឹតតែមានន័យកាន់តែក្បោះក្បាយ បន្ទាប់ពីរបានរៀបចំផែនការ និងយុទ្ធសាស្ត្រគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន អិន ស៊ី អិច រួចមកយើងអាចទាញបានចំណុចខ្លាំង និងចំណុចខ្សោយដូចខាងក្រោម៖

## ៤.១.ការវិភាគលើចំណុចខ្លាំង

- ក្រុមហ៊ុនអាចគ្រប់គ្រងលំហូរសាច់ប្រាក់ដោយដឹងពីចំណូល និងចំណាយយ៉ាងច្បាស់លាស់។
- រាល់ចំណាយទាំងអស់ដែលកើតមានឡើងនៅក្នុងក្រុមហ៊ុន គឺត្រូវបានផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ពីផ្នែកគណនេយ្យដើម្បីធ្វើការបិទបញ្ជី និងប្រកាសពន្ធ ចំណេញ ខាត។
- ការគ្រប់គ្រងសាច់ប្រាក់មានលក្ខណៈច្បាស់លាស់ទៅតាមក្បួនច្បាប់គណនេយ្យ(Accounting Policy)។
- ក្រុមហ៊ុនបានរៀបចំគម្រោងចំណាយសាច់ប្រាក់បានយ៉ាងច្បាស់លាស់មុន និងអនុវត្តការចំណាយដោយគោរពតាមគោលការណ៍គណនេយ្យបានយ៉ាងល្អ។
- ការរៀបចំគម្រោងចំណាយសាច់ប្រាក់ប្រចាំឆ្នាំ គឺទទួលបាននូវប្រសិទ្ធភាពខ្ពស់ ដោយអត្រាចំណាយសាច់ប្រាក់ទាបជាងប្រភពចំណូល ដែលជាហេតុធ្វើឱ្យក្រុមហ៊ុនមានភាពរីកចម្រើន។
- ធ្វើឱ្យក្រុមហ៊ុនមានសមត្ថភាពក្នុងការពង្រីងទំហំអាជីវកម្មរបស់ខ្លួនឱ្យធំជាងមុន។
- រាល់ឯកសារចំណាយទាំងអស់ត្រូវបានគ្រប់គ្រងបានយ៉ាងល្អមានសណ្ដាប់ធ្នាប់ និងរក្សាទុករបាយការណ៍តាមឆ្នាំនីមួយៗ ដើម្បីផ្ទៀតផ្ទាត់ និងការពារការបន្លំឯកសារមកប្រើប្រាស់ម្ដងទៀត។
- ការគ្រប់គ្រងចំណូល និងចំណាយរបស់ក្រុមហ៊ុនមានភាពហ្មត់ចត់ អាចជួយទប់ស្កាត់ហានិភ័យរបស់ក្រុមហ៊ុនដែលកើតឡើងចំពោះមុខបាន។

## ៤.២ ការវិភាគលើចំណុចខ្សោយ

- កត្តាកង្វះខាតបុគ្គលិកជំនាញ ដែលធ្វើឱ្យការផលិតទំនិញជូនអតិថិជន មានភាពយឺតយ៉ាវមិនទាន់ពេលវេលាធ្វើអោយក្រុមហ៊ុនជួបនូវវិបត្តិកង្វះខាតសាច់ប្រាក់។
- ក្រុមហ៊ុនមានដៃគូរប្រកួតប្រជែងច្រើនពិបាកក្នុងការវាយលុកក្នុងទីផ្សារ ក្រុមហ៊ុនកង្វះបុគ្គលិកដែលមានជំនាញច្បាស់លាស់ក្នុងការវិភាគបញ្ហាម៉ូតូរបស់អតិថិជនដែលនាំឱ្យប្រាក់ចំណូលពីផ្នែកសេវាកម្មជួសជុលមានការធ្លាក់ចុះ។
- ប្រភពនៃការចំណាយរបស់ក្រុមហ៊ុន គឺមានការកើនឡើងដោយយើងសង្កេតឃើញថាការចំណាយពីមួយថ្ងៃទៅមួយថ្ងៃមានការប្រែប្រួលទៅតាមទំហំរបស់ក្រុមហ៊ុន។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវ និងបានសាកសួរយ៉ាងលម្អិតដែលទាក់ទង និងប្រធានបទដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អិន ស៊ី អិច រួចហើយខ្ញុំបានយល់ដឹងបានយ៉ាងច្រើន និងឆ្លើយតបទៅនឹងចំណោទបញ្ហាដែលបានចោទសួរមកពីខាងដើម។ ចំណុចមួយទៀត គឺអាចឱ្យយើងរកឃើញនូវតម្លាភាពចំណុចខ្លាំង និងចំណុចខ្វះខាត មួយចំនួនក្នុងការគ្រប់គ្រងសាច់ប្រាក់ និងយុទ្ធសាស្ត្រនានារបស់ក្រុមហ៊ុន អិន ស៊ី អិច ក្នុងរយៈពេលកន្លងមក។ ក្រោយពីបានសិក្សារួចមកធ្វើឱ្យខ្ញុំយល់ច្បាស់ថាក្រុមហ៊ុន អិន ស៊ីអិច ដែលជាក្រុមហ៊ុនផ្គត់ផ្គង់ និងចែកចាយម៉ូតូធំជាងគេនៅក្នុងចំណោមក្រុមហ៊ុនជាច្រើននៅប្រទេសកម្ពុជាដែលមានការគាំទ្រពីអតិថិជនដោយពួកគេទទួលស្គាល់ថាក្រុមហ៊ុននេះ គឺគោរពទៅតាមច្បាប់មានឧបករណ៍ការពារបរិស្ថានល្អ គុណភាពនៃគ្រឿងចក្រមានគុណភាពខ្ពស់ គឺមិនដែលផ្តល់ទំនិញឱ្យយឺតពេលដល់អតិថិជនឡើយនេះសបញ្ជាក់ឱ្យឃើញថាក្រុមហ៊ុន អិន ស៊ី អិច មានការគ្រប់គ្រងនឹងចាត់ចែងការងារបានល្អទាំងការគ្រប់គ្រងលើផ្នែកធនធានមនុស្ស ជាពិសេសទៅទៀតទៅលើការគ្រប់គ្រងការចំណាយប្រាក់ដែលកើនឡើងជារៀងរាល់ថ្ងៃក្នុងប្រតិបត្តិការ។ ម្យ៉ាងវិញទៀតអ្នកដឹកនាំមានរបៀបនៃការគ្រប់គ្រងសាច់ប្រាក់ និងធ្វើយ៉ាងណាឱ្យប្រតិបត្តិការសាច់ប្រាក់មានដំណើរការល្អប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលជារបាយការណ៍មួយសម្រាប់ធ្វើការគ្រប់គ្រង និងតាមដាននូវលំហូរចំណាយសាច់ប្រាក់របស់ក្រុមហ៊ុនពិតជាមានលក្ខណៈល្អប្រសើរសមស្របតាមស្តង់ដារអន្តរជាតិដោយក្រុមហ៊ុនបានអនុវត្តបានយ៉ាងត្រឹមត្រូវទៅតាមគោលការណ៍គណនេយ្យដែលគេទទួលស្គាល់ទូទៅនាំឱ្យមានភាពងាយស្រួលដល់អ្នកខាងក្រៅ ដើម្បីពិនិត្យនិងស្វែងយល់ឱ្យកាន់តែច្បាស់លាស់ពីរបាយការណ៍នោះ។ ចំពោះរបាយការណ៍ទាំងនេះបានភ្ជាប់មកជាមួយនូវរបាយការណ៍លម្អិតផ្សេងៗទៀតជាច្រើនទៅតាមប្រភេទគណនីនីមួយៗហើយក៏បានសង្កេតឃើញថារាល់ការចំណាយទាំងអស់របស់ក្រុមហ៊ុន គឺពឹងផ្អែកទាំងស្រុងទៅលើ របាយការណ៍ហិរញ្ញវត្ថុ។ ក្រោយការវិភាគរបាយការណ៍របស់ក្រុមហ៊ុនយើងអាចធ្វើការសន្និដ្ឋានបានទៅលើចំណុចដែលបានកំណត់ការស្រាវជ្រាវ និងវាយតម្លៃឡើងវិញនៃប្រតិបត្តិការនោះ គឺការបង្កើនចំណូល និងគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុនឱ្យមានការរីកចម្រើនដែលការរីកចម្រើននេះ គឺជាចំណែកមួយធំដែលបានមកពីការរៀបចំ គម្រោងចំណាយច្បាស់លាស់របស់ក្រុមហ៊ុន។

## ៥.២ ការផ្តល់អនុសាសន៍

យោងទៅតាមការវិភាគទៅលើចំណុចខ្សោយក៏ដូចជាការបកស្រាយ រួមទាំងការសន្និដ្ឋានខាងលើក្រុមសិក្សាស្រាវជ្រាវសោណាមាននូវគំនិត និងយោបល់មួយចំនួនដើម្បីឱ្យក្រុមហ៊ុនធ្វើការពិចារណា និងធ្វើការកែប្រែជាថ្មីដើម្បីឱ្យការផលិតយានយន្តមានភាពទាន់សម័យ និងទទួលបានប្រាក់ចំណេញកាន់តែច្រើន។

- ក្រុមហ៊ុនគួរតែធ្វើការបែងចែកប្រភេទចំណូលឱ្យបានច្បាស់លាស់ ដូចជា ចំណូលពីការលក់ និងចំណូលពីការផ្តល់សេវាកម្ម។
- ក្រុមហ៊ុនគួរតែពិនិត្យទៅលើថ្លៃដើមទំនិញដែលមានការប្រែប្រួលជារៀងរាល់ឆ្នាំ ជៀសវាងក្នុងការកើនឡើង និងថយចុះនៃថ្លៃដើមខុសប្រក្រតី។
- ក្រុមហ៊ុនគួរតែយកចិត្តទុកដាក់ទៅលើការប្រមូលទឹកប្រាក់ដែលអតិថិជនជំពាក់ ព្រោះទឹកប្រាក់ត្រូវទារមានចំនួនច្រើនលើសលប់ពេក ដែលអាចបង្កជាហានិភ័យសម្រាប់ក្រុមហ៊ុន

# ឯកសារយោង

# ឯកសារយោង

សៀវភៅសារណារបស់រៀមច្បងយកពីបណ្ណាល័យរបស់ **សាកលវិទ្យាល័យវ៉ាន់ដា**


1. ឈួយ ស្រីឡឹម.(2024). *ការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុនហុងដា.* របាយការណ៍បញ្ចប់ថ្នាក់បរិញ្ញបត្រជាន់ខ្ពស់នៃវិទ្យាស្ថាន វ៉ាន់ដា ទំព័រទី១០ ទីកន្លែងបោះពុម្ព រាជធានីភ្នំពេញ។
2. អិន ស៊ី អិច ខូអិលធីឌី. (2025). *អំពីក្រុមហ៊ុន អិន ស៊ី អិច.* Retrieved from https://www.ncxhonda.com/kh/corporate-profile
3. អង្គភាពសវនកម្មផ្ទៃក្នុង. (2024, October). *វិធីសាស្ត្រគ្រប់គ្រងសាច់ប្រាក់.* Retrieved from https://iauoffsa.gov.kh/wp-content/uploads/2024/10/
4. កោះសន្តិភាព. (2015, November 20). *ការគ្រប់គ្រងសាច់ប្រាក់ឱ្យមានប្រសិទ្ធភាព.* Retrieved from https://kohsantepheapdaily.com.kh/article/133869.html
5. វិគីភីឌា. (2020, June 08). *ប្រវត្តិហិរញ្ញវត្ថុ.* Retrieved from https://km.wikipedia.org
6. សហគ្រិនខ្មែរ. ( 2022, March 03). *យុទ្ធសាស្ត្រទីផ្សារទាំង៥.* Retrieved from https://images.app.goo.gl/t2qKdRtPZ8cNKoCR8
7. LAWANDMORE. (2025). *ហិរញ្ញវត្ថុជាអ្វី?* Retrieved from https://lawandmore.today/
8. គំរូអជីវកម្ម .(2021 August 03). *ស្តេចក្តីរីករាយទាំង៣របស់ក្រុមហ៊ុន.* Retrieved from https://www.bloomberg.com/profile/person/18935740
9. KHsearch.com. គ្រប់គ្រង. (2020, January 11). *ដូចម្តេចដែលហៅថាផែនការ?* Retrieved from https://www.khsearch.com/qna/28221
10. KHsearch. គ្រប់គ្រង. (2020, May 29). *យុទ្ធសាស្ត្រជាអ្វី?* Retrieved from https://www.khsearch.com/qna/31418
11. Library of Royal University of Law and economics. (2020 June 20). *អ្វីទៅជាចំណូល?* Retrieved from https://www.facebook.com/photo.php?fbid=4297751153583315&id=1149435801748215&set=a.1149438368414625&locale=km_KH
12. LUYBOOK. (2025). *ប្រភេទចំណូលទាំង៨.* Retrieved from https://luy-book.com/2022/07/17/types-of-income/
13. N.C.X spare-part. (2025). *គ្រឿងបន្លាស់សុទ្ធហុងដា.* Retrieved from https://www.ncxhonda.com/motorcycles/kh/spare-part
14. WordPress.com. (2013, February 16). *យុទ្ធសាស្ត្រជាអ្វី?* Retrieved from https://socheatorganization.wordpress.com/2013/02/16/
15. WIKIPEDIA. (22 August 2025). Retrieved from https://en.wikipedia.org/wiki/Soichiro_Honda
16. Media Newsroom. CEO Toshihiro Mibe. *ប្រវត្តិប្រធានក្រុមហ៊ុនបច្ចុប្បន្ន.* Retrieved March, 14 2025from https://hondanews.com/en-US/releases/toshihiro-mibe
17. Litefinance. (2024, April). *ប្រភេទនៃការធ្វើហិរញ្ញវត្ថុ.* Retrieved from https://litefinance-kh.com/blog/for-beginners/tae-phenkar-heronhnhovottho-chea-avei/

18. Litefinance. Jana Kane. (2024, April). *ជាតុផ្សំសំខាន់នៃការធ្វើផែនការហិរញ្ញវត្ថុ*. Retrieved from https://litefinance-kh.com/blog/for-beginners/tae-phenkar-heronhnhovottho-chea-avei/
19. thmeythmey.com. (2017, December 24). *យុទ្ធសាស្ត្រជាអ្វី?* Retrieved from https://thmeythmey.com/detail/59938
20. BIRMISS. (2018). *ទ្រឹស្ដីហិរញ្ញវត្ថុ*. Retrieved from https://km.birmiss.com/

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

- **LOGO របស់ក្រុមហ៊ុន អិនស៊ីអិច ខូអិលធីឌី**

- ទីតាំងរបស់ក្រុមហ៊ុន អិនស៊ីអិច ខូអិលធីឌី




N.C.X.CO.,LTD.



Honda Dream 2025

Honda Scoopy 2025



Honda Super Cub 2025




PGM-FI
PROGRAMMED FUEL INJECTION
គ្រប់ផលិតផលកំពូលៗរបស់ហុងដា
សុទ្ធតែប្រើប្រាស់នូវប្រព័ន្ធបិចសាំង ឬ PGM-FI

